

# មតិមហាជន ស្តីពីការ

## ថែរក្សាឯកសារ តុលាការកាត់ទោស មេដឹកនាំជាន់ខ្ពស់ ខ្មែរក្រហម


សិក្សាស្ទង់មតិដោយ
បណ្តាញអភិវឌ្ឍន៍ជំនួញកម្ពុជា

បោះពុម្ពផ្សាយដោយ DC-CAM
The Documentation Center of Cambodia

ខែកញ្ញា ឆ្នាំ២០១៩



**ការបដិសេធទទួលខុសត្រូវ**

២០១៩ ក្រុមហ៊ុនបណ្តាញអភិវឌ្ឍន៍មុខជំនួញ (កម្ពុជា) ខូអិលធីឌី។ រក្សាសិទ្ធិគ្រប់យ៉ាង។

ដោយសារតែមូលហេតុក្នុងការរក្សាការសម្ងាត់ព័ត៌មានស្តីពីអត្តសញ្ញាណរបស់បុគ្គលមិនត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះទេ។ លើសពីនេះទៅទៀត ការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងត្រូវបានធ្វើឡើងដើម្បីធានាភាពត្រឹមត្រូវនៃព័ត៌មាន និងការវិភាគនៅក្នុងរបាយការណ៍នេះ ប៉ុន្តែយ៉ាងណាក៏ដោយ អ្នកនិពន្ធនិងក្រុមហ៊ុនដែលអ្នកនិពន្ធតំណាងឲ្យ មិនទទួលខុសត្រូវចំពោះរាល់កំហុសឆ្គងដោយអចេតនា ការលុបចោល ឬសេចក្តីថ្លែងការណ៍បំភាន់ណាមួយឡើយ។ ទស្សនៈដែលបានបង្ហាញនៅក្នុងរបាយ-ការណ៍នេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ក្រុមហ៊ុនបណ្តាញអភិវឌ្ឍន៍ជំនួញទេ។ ដូច្នេះ ក្រុមហ៊ុនបណ្តាញអភិវឌ្ឍន៍ជំនួញនឹងមិនទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុក្តីឬផ្នែកផ្សេងៗទៀតក្តីលើផលវិបាកណាមួយដែលកើតចេញពីការប្រើប្រាស់របាយការណ៍នេះឡើយ។

**រូបថតក្របមុខ៖** បន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ប្រភពរូបថត៖** បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៥

**ឌុចកាំង ហ្គេកអ៊ាវ ហៅ ឌុច**

កើតនៅឆ្នាំ១៩៤២ បានចូលរួមក្នុងចលនាកុម្មុយនិស្តនៅក្នុងឆ្នាំ១៩៦៤។ ឌុច បានធ្វើជាគ្រូបង្រៀនផ្នែកគណិតវិទ្យានៅក្នុងឆ្នាំ១៩៦៥។ នៅឆ្នាំ១៩៦៧ ឌុច បានបោះបង់អាជីពជាគ្រូបង្រៀនរបស់ខ្លួនទាំងស្រុង ហើយបានចូលរួមក្នុងចលនាតស៊ូសម្ងាត់។ ឌុច ត្រូវបានចាប់ខ្លួននៅដើមឆ្នាំ១៩៦៨ ពីបទធ្វើឲ្យប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សន្តិសុខជាតិ ហើយត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ។ ឌុច បានឆ្លើយផ្តល់សក្ខីកម្មនៅក្នុងមន្ទីរឃុំឃាំងប៉ុន្តែមិនត្រូវបានធ្វើទារុណកម្មនិងយកទៅសម្លាប់ចោលឡើយ។ នៅថ្ងៃទី១៨ ខែមីនាឆ្នាំ ១៩៧០ លោកសេនាប្រមុខ លន់ ណុល បានធ្វើរដ្ឋប្រហារយោធាផ្តួលរំលំរបបសម្តេចព្រះនរោត្តមសីហនុ។ ដោយមានការគាំទ្រពីសហរដ្ឋអាមេរិក លន់ ណុល បានគ្រប់គ្រងប្រទេសរហូតដល់ខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ឌុច ត្រូវបានដោះលែងពីពន្ធនាគារខែមេសាឆ្នាំ១៩៧០ ហើយបន្ទាប់មក ឌុច ក៏បានបន្តសកម្មភាពនៃចលនាសម្ងាត់របស់គាត់បន្តទៅទៀត។ ក្នុងខែ កក្កដា ឆ្នាំ១៩៧១ ឌុច ត្រូវបានតែងតាំងជាប្រធានមន្ទីរម-១៣ ដែលទីនោះគឺជាមន្ទីរសន្តិសុខមួយដែលមានភារកិច្ចសួរចម្លើយអ្នកស៊ើបការណ៍ឬសត្រូវនៃចលនារបស់ខ្មែរក្រហម។ តួនាទីរបស់ ឌុច គឺបានស្ថិតនៅក្នុងចំណារការងាររបស់ខ្លួនរហូតដល់ចុងបញ្ចប់នៃរបបនេះ។ ក្នុងនាមជាប្រធានមន្ទីរសន្តិសុខ ឌុច បានជ្រើសរើសយុវជនពីក្នុងចំណោមកសិករក្រីក្រហើយបានបណ្តុះបណ្តាលពួកគេទាំងនោះនូវបច្ចេកទេសសួរចម្លើយ។ ឌុច បានត្រួតពិនិត្យនូវរាល់ការសួរចម្លើយដែលធ្វើឡើងដោយបុគ្គលិករបស់ខ្លួន ដោយប្រើនូវអំពើហឹង្សាដូចជាការវាយនឹងមែកឫស្សី ហើយចម្លើយសារភាពទាំងអស់នោះត្រូវបានបញ្ជូនទៅថ្នាក់លើរបស់ខ្លួន។ ឌុច ត្រូវបានតែងតាំងជាអនុប្រធានទីមួយនៅមន្ទីរស-២១។ នៅខែមីនាឆ្នាំ១៩៧៦ ឌុចត្រូវបានតែងតាំងជាប្រធានមន្ទីរស-២១ ហើយ ឌុច បានស្ថិតក្នុងតួនាទីនេះរហូតមកទល់នឹងការដួលរលំនៃរបបរបស់ខ្លួននៅខែមករាឆ្នាំ១៩៧៩។ ក្នុងតួនាទីជាប្រធានមន្ទីរសន្តិសុខស-២១ ឌុច បានទទួលសិទ្ធិអំណាចពេញលេញលើការគ្រប់គ្រងបុគ្គលិករបស់ខ្លួន ហើយដែលក្រោយមកអ្នកខ្លះក៏បានក្លាយទៅជាជនរងគ្រោះនៅក្នុងវិធីសាស្រ្តនិងបទពិសោធន៍ការងារដ៏ម្មតចត់ដូចគ្នានឹងជនរងគ្រោះដែលបានកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលកងកម្លាំងរំដោះបានជិតចូលមកដល់ ឌុច និងអ្នកក្រោមបង្គាប់របស់ខ្លួន រួមទាំងអ្នកជាប់ឃុំប្រមាណ១៥នាក់បានភៀសខ្លួនចេញពីមន្ទីរស-២១។ ឌុច និងក្រុមពួកខ្មែរក្រហមដែលរត់គេចខ្លួន បានរត់ភៀសខ្លួនទៅកាន់ព្រំដែនភាគខាងលិចនៃប្រទេសកម្ពុជា។ ឌុច នៅតែបម្រើឲ្យចលនាកុម្មុយនិស្តរហូតដល់ដើមទសវត្សឆ្នាំ១៩៩០។ ក្រោមការផ្លាស់ប្តូរអត្តសញ្ញាណថ្មី ឌុច ចាប់ផ្តើមអាជីពថ្មីរបស់គាត់ជាគ្រូបង្រៀន។ នៅឆ្នាំ១៩៩៦ គាត់ត្រូវបានឧទ្ទិសថ្វាយខ្លួនផ្លាស់ប្តូរសាសនា ហើយបានក្លាយជាគ្រិស្តសាសនិកចាប់ពីពេលនោះមក។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ឌុច ត្រូវបានចាប់ខ្លួន និងបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងនៅក្នុងតុលាការយោធាកម្ពុជាពីបទចោទប្រកាន់ផ្សេងៗ (ដកស្រង់ចេញសៀវភៅដែលមានចំណងជើងថា WHEN THE CRIMINAL LAUGHS ដោយ ជី ទេវិទ្ធិ)។

នៅខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានកាត់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលជាទោសអតិបរមាហើយមានចែងនៅក្នុងច្បាប់ សម្រាប់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

*ថតរូបដោយ៖ អេង កុកថាយ (បណ្ណសារដ្ឋានមជ្ឈមណ្ឌកសារកម្ពុជា)*

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ស្ទួន ផៅរ៉េ ទីប្រឹក្សាយោបល់របស់ក្រុមហ៊ុនបណ្តាញអភិវឌ្ឍន៍ជំនួញ ចំពោះការផ្តល់អនុសាសន៍និងការកែសម្រួលរបាយការណ៍នេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្ឌិត ម៉ាគើស ហ្សិមម័រ, សូ ហ្វារីណា, រស់ សំពៅ និង វ៉ា សុធី ចំពោះការផ្តល់មតិយោបល់និងអនុសាសន៍នានា ក្នុងអំឡុងពេលសរសេរ កែសម្រួល និងបញ្ចប់របាយការណ៍នេះ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ វ៉ាន់ថាន់ ពៅដារ៉ា ដែលបានផ្តល់មតិគាំទ្រគម្រោងស្ទង់មតិយោបល់នេះ តាំងពីពេលចាប់ផ្តើមគម្រោងដំបូង។ របាយការណ៍នេះ នឹងមិនអាចចេញជារូបរាងបានឡើយ ប្រសិនបើគ្មានការចូលរួមរបស់ អ៊ុំ ច័ន្ទមនោ ក្នុងការរៀបចំរចនានិងការកែសម្រួលកម្រងសំណួរ។ លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ៊ំពូមីងនិស្សិតសាស្រ្តាចារ្យនិងលោក-លោកស្រីអ្នកនាងកញ្ញាដែលបានចំណាយពេលវេលាចូលរួមនៅក្នុងការសិក្សាស្ទង់មតិនេះ។ ជាចុងក្រោយ ការសិក្សាស្ទង់មតិនេះ នឹងមិនអាចបញ្ចប់បានដោយពេញលេញទេ ប្រសិនបើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចិមទិស (EWMI) តាមរយៈគម្រោងការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា (CCSS)។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិករបស់ក្រុមអ្នកសិក្សាស្រាវជ្រាវទាំងអស់ដែលរួមមាន៖ ឆន ចាន់ធី ជាអ្នករៀបចំនិងសរសេររបាយការណ៍, សារ៉ាក់ ពិសិដ្ឋ និង សួង ស៊ីដេត ជាអ្នកគ្រប់គ្រងនិងត្រួតពិនិត្យក្រុមការងារនៅតាមមូលដ្ឋាន និង សេង ស្រីពៅ ជាអ្នកគ្រប់គ្រងនិងត្រួតពិនិត្យទិន្នន័យ និងសមាជិក១៤នាក់ផ្សេងទៀត ដែលបានធ្វើការខិតខំប្រឹងប្រែងដ៏ធំធេងរហូតទាល់តែការសិក្សាស្ទង់មតិនេះសម្រេចបានជោគជ័យ។

របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០១៩

**ការបដិសេធទទួលខុសត្រូវ**

របាយការណ៍នេះ អាចចេញជាលទ្ធផលបានដោយសារជំនួយសប្បុរសរបស់ប្រជាពលរដ្ឋសហរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ ខ្លឹមសារនៃរបាយការណ៍នេះជាការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចិមទិស, ទីភ្នាក់ងារតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកនោះទេ។

USAID
FROM THE AMERICAN PEOPLE

# សេចក្តីសង្ខេប

គោលបំណងនៃការសិក្សាស្ទង់មតិនេះ គឺដើម្បីពិនិត្យមើលមតិសាធារណៈរបស់ប្រជាជនកម្ពុជាអំពីការរៀបចំថែរក្សាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

ការរក្សាទុកនិងការថែទាំបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំពុងតែក្លាយជាប្រធានបទមួយសម្រាប់ជជែកដេញដោលគ្នាក្នុងពេលបច្ចុប្បន្ន។ ក្នុងបរិបទនេះ ការយល់ដឹងអំពីការយល់ឃើញរបស់ប្រជាជនទាក់ទងនឹងការថែរក្សាកំណត់ត្រាប្រវត្តិសាស្ត្រទាំងអស់នេះ ពិតជាមានសារៈសំខាន់ណាស់ ជាពិសេស ទស្សនៈផ្ទាល់របស់ប្រជាជនជុំវិញភាពចាំបាច់ទុកដាក់បណ្ណសារទាំងនោះ ក្រោមការថែរក្សាដោយស្ថាប័នណាមួយដែលគួរឱ្យទុកចិត្តបាន និងឯករាជ្យមិនស្ថិតក្រោមឥទ្ធិពលបុគ្គលឬនយោបាយ ដែលអាចបណ្តាលឲ្យមាតិកានៃបណ្ណសារទាំងនោះរងការផ្លាស់ប្តូរ, កែសម្រួលខុសភាពដើម ឬត្រូវបានកម្ទេចចោល និងជាស្ថាប័នមួយដែលមានធនធាន និងអាយុកាលយូរអង្វែង ដើម្បីធានាយ៉ាងណាឱ្យបណ្ណសាររក្សាបានបូរណភាព និងមានសន្តិសុខពេញលេញជារៀងរហូត។

លើសពីនេះទៅទៀត ការសិក្សាស្ទង់មតិនេះបានផ្តល់ឱកាសជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបង្កើតផែនការនិងយុទ្ធសាស្ត្រការងារសម្រាប់រយៈពេលវែង ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ ក៏ដូចជាផ្សព្វផ្សាយអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងការងាររបស់មជ្ឈមណ្ឌល។ ការសិក្សាស្ទង់មតិនេះបានផ្តោតសំខាន់ទៅលើទិន្នន័យបែបបរិមាណ ព្រមទាំងត្រូវបានបំពេញបន្ថែមដោយទិន្នន័យបែបគុណភាពដើម្បីទទួលបាននូវការយល់ដឹងដ៏ស៊ីជម្រៅមួយ។

ដើម្បីផ្តល់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីការយល់ឃើញជាសាធារណៈចំពោះបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រជាជនដែលជាសំណាកនៃការសិក្សាដែលត្រូវបានទាក់ទងនឹងសម្ភាសន៍ រួមមាន៖ ប្រជាជនទូទៅ (សាធារណជន) អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អតីតកម្មាភិបាលខ្មែរក្រហម និស្សិតនិងសាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ ព្រមទាំងអ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនទៀត។

ការចុះទៅបំពេញការងារនៅមូលដ្ឋានសម្រាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវប្រើរយៈពេលជាងពីរខែ គឺចាប់ពីខែមេសា រហូតដល់ខែឧសភា ឆ្នាំ២០១៩។ ដោយមិនរាប់បញ្ចូលនូវបទសម្ភាសន៍ពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ ក្រុមការងារស្ទង់មតិ បានសម្ភាសអ្នកចូលរួមសរុបទាំងអស់ចំនួន ១.៥៥៧នាក់ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ដោយក្នុងនោះរួមមាន៖ ៧៥៩នាក់រស់នៅទីជនបទ និង៧៩៨នាក់ រស់នៅទីប្រជុំជននានាក្នុងខេត្តដែលមានប្រជាជនច្រើនចំនួន ព្រមទាំងរាជធានីភ្នំពេញ។ យោងតាមការបែងចែកតាមភេទ គំរូសំណាកមានបុរសចំនួន ៧៧១នាក់ និងស្ត្រីចំនួន ៧៨៦នាក់។

## /// លទ្ធផលសំខាន់ៗនៃការស្រាវជ្រាវ

### ការយល់ឃើញចំពោះរបបខ្មែរក្រហម

- អ្នកចូលរួមភាគច្រើនយល់ឃើញថាអ្នកទទួលខុសត្រូវលើរបបខ្មែរក្រហម និងបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គួរតែត្រូវបានផ្តន្ទាទោសតាមផ្លូវច្បាប់ (៩២ភាគរយ នៃអ្នកចូលរួមសរុប)។ ទន្ទឹមនឹងនេះដែរ អ្នកចូលរួមភាគច្រើន (មិនមែនទាំងអស់ទេ)បានអភ័យទោស ឬបានត្រៀមខ្លួនរួចរាល់សម្រាប់អភ័យទោស ដល់អ្នកទទួលខុសត្រូវលើរបបនេះ (គឺមាន ៥៧ភាគរយនៃអ្នកចូលរួមសរុប) ។
- អ្នកចូលរួម បានបង្ហាញអារម្មណ៍ស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះខ្មែរក្រហម ដែលទទួលខុសត្រូវលើអំពើហិង្សា (គឺមាន ៨៧ភាគរយនៃអ្នកចូលរួមសរុប)។ ម្យ៉ាងវិញទៀត អ្នកចូលរួមមួយចំនួនតូច បានបង្ហាញពីបំណងចង់សងសឹកចំពោះខ្មែរក្រហម (គឺមាន២៣ភាគរយនៃអ្នកចូលរួមសរុប ដោយមានពីចន្លោះ១៧ភាគរយនៃអ្នកចូលរួមដែលជានិស្សិត និងសាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ ទៅដល់ ២៧ភាគរយនៃអ្នកចូលរួមដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម)។

### ការយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ សាលាក្តីខ្មែរក្រហម

- អ្នកចូលរួមប្រមាណជាង៨៣ភាគរយធ្លាប់បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម (ដោយភាគច្រើនទំនងជាធ្លាប់បានឮអំពីសាលាក្តីខ្មែរក្រហម ជាជាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។ ភាគច្រើននៃអ្នកដែលស្គាល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម បានដឹងច្បាស់អំពីតួនាទីចម្បងនិងលក្ខណៈពិសេសរបស់តុលាការនេះ (តុលាការចម្រុះអន្តរជាតិនិងកម្ពុជា) ។ ប្រមាណជាងពាក់កណ្តាលនៃចំនួនអ្នកចូលរួមខាងលើបានដឹងថាស្ថាប័ននេះបានទទួលជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលកម្ពុជានិងម្ចាស់ជំនួយបរទេសនានា។



### ស្ថាប័នណាមួយដែលគួរថែរក្សាបណ្ណសាររបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

- ក្នុងការសិក្សាស្ទង់មតិនេះ ស្ថាប័នដែលមានប្រជាជនស្គាល់ច្រើនរួមមាន៖ បណ្ណាល័យជាតិ បណ្ណាល័យហ៊ុនសែន និងមជ្ឈមណ្ឌលឯកសារកម្ពុជា។
- អ្នកចូលរួមប្រហែលជាង ៩៦ភាគរយ គិតថាកិច្ចការថែរក្សាឯកសារដំណើរការនានា និងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងទីតាំងណាមួយដែលប្រកបដោយសុវត្ថិភាពនិងមានការការពារសុវត្ថិភាពខ្ពស់ គឺពិតជាមានសារៈសំខាន់ណាស់។
- អ្នកចូលរួមជឿជាក់ថា ស្ថាប័នដែលទទួលបន្ទុកថែរក្សានិងការពារសុវត្ថិភាពបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវតែគួរជាទីទុកចិត្តនិងទទួលបានការជឿជាក់ពីសំណាក់ប្រជាជនកម្ពុជា ហើយព្រមទាំងឯករាជ្យនិងអព្យាក្រឹត ក៏ដូចជាផ្តល់នូវភាពងាយស្រួលដល់ប្រជាជនកម្ពុជាក្នុងការប្រើប្រាស់ឯកសារ។ លើសពីនេះទៅទៀត ស្ថាប័នតម្កល់បណ្ណសារនេះ គឺមិនត្រូវមានទំនាក់ទំនងឬសម្ព័ន្ធភាពផ្នែកនយោបាយណាមួយឡើយ។ អ្នកផ្តល់ព័ត៌មានសំខាន់ៗដែលត្រូវបានសម្ភាសសម្រាប់ការសិក្សាស្ទង់មតិនេះ ជឿជាក់ថាជារឿងសំខាន់ណាស់ដែលស្ថាប័នគ្រប់គ្រងបណ្ណសារនេះត្រូវមានបច្ចេកវិទ្យាចាំបាច់ក្នុងការផ្ទុកទិន្នន័យ (ទីតាំងផ្ទុកទិន្នន័យក្នុងបច្ចេកវិទ្យាខ្លោតកម្មវិធីផ្ទុកទិន្នន័យលើអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព និងមណ្ឌលផ្ទុកទិន្នន័យសុវត្ថិភាព) ព្រមទាំងមានធនធានមនុស្សមានសមត្ថភាពផ្នែកបច្ចេកទេសចាំបាច់សម្រាប់បំប្លែងបណ្ណសារទៅជាឯកសារឌីជីថល (Digitalize) និងជួយសម្រួលដល់សាធារណជននូវការចូលប្រើបណ្ណសារតាមរយៈអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព។
- ស្ថាប័នកំពូលទាំងបួនដែលអ្នកចូលរួម មានបំណងចង់ឲ្យរក្សាទុកបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានដូចជា៖ បណ្ណាល័យជាតិ មជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណាល័យហ៊ុនសែន និង បណ្ណាល័យរបស់ក្រសួងយុត្តិធម៌។ អ្នកផ្តល់ព័ត៌មានសំខាន់ដែលត្រូវបានសម្ភាស យល់ឃើញថា បណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវតែរក្សាទុកនៅក្នុងប្រទេសកម្ពុជា (មិនមែននៅបរទេសទេ) ហើយការរួមសហការរវាងស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានាគឺពិតជាចាំបាច់ណាស់។ ស្ថាប័នរដ្ឋាភិបាលគួរតែទទួលខុសត្រូវលើការថែរក្សាសុវត្ថិភាពបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯអង្គការសង្គមស៊ីវិលគួរតែជួយលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីបណ្ណសារនេះ។ អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួន បានលើកឡើងថា បណ្ណសារនេះគួរតែត្រូវបានរក្សាទុកដោយស្ថាប័នណាមួយដែលមានជំនាញផ្នែកច្បាប់ និង/ឬ មានជំនាញក្នុងការរក្សាទុកឯកសារស្តីពីការចងចាំ និងប្រវត្តិសាស្ត្រ។ ទន្ទឹមនឹងនេះ ក៏មានការលើកឡើងដែរថា គួរតែបង្កើតឲ្យមានគណៈកម្មាធិការមួយដែលប្រកបដោយអភិបាលកិច្ចល្អនិងតម្លាភាពរឹងមាំ ដើម្បីគ្រប់គ្រង និងរក្សាសុវត្ថិភាពបណ្ណសារនេះ។

### ការយល់ដឹងអំពីមជ្ឈមណ្ឌល និងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

- ក្នុងចំណោមអ្នកចូលរួមដែលធ្លាប់បានឮអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា មានអ្នកចូលរួមមួយចំនួន តូចតែប៉ុណ្ណោះដែលធ្លាប់បានចូលរួមសកម្មភាព ឬព្រឹត្តិការណ៍ណាមួយដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬធ្លាប់បានធ្វើទស្សនកិច្ចដោយផ្ទាល់នៅការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ប្រើត្បិតតែមានការចូលរួមផ្ទាល់តិចតួចជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកចូលរួមភាគច្រើនមានទស្សនៈវិជ្ជមានចំពោះតួនាទីនិងកេរ្តិ៍ឈ្មោះរបស់អង្គការនេះ ដែលក្នុងនោះរួមមានតួនាទីរបស់អង្គការក្នុងការជួយថែរក្សាប្រវត្តិសាស្ត្រកម្ពុជា និងការស្វែងរកការពិតអំពីរបបខ្មែរក្រហម។

សរុបសេចក្តីមកមជ្ឈមណ្ឌលឯកសារកម្ពុជាឬស្ថាប័នដទៃទៀតដែលនឹងថែរក្សាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែបន្តលើកកម្ពស់ភាពគួរជាទីទុកចិត្ត អព្យាក្រឹតភាព ឯករាជ្យភាព និងភាពគួរឲ្យជឿជាក់របស់ខ្លួន និងគួរតែបន្តបង្កើនសមត្ថភាពបច្ចេកទេសរបស់ខ្លួនក្នុងការថែរក្សានិងតម្កល់ទុកបណ្ណសារនេះ។ ស្ថាប័នក៏គួរតែបន្តលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការងារ ទីតាំង ព្រឹត្តិការណ៍ ឬកម្មវិធីផ្សេងៗរបស់ខ្លួនដែរ។ លើសពីនេះទៅទៀត ការបង្កើតនិងការអនុវត្តគោលនយោបាយច្បាស់លាស់មួយ ដើម្បីរក្សានិរន្តរភាព និងកេរដំណែលរបស់បណ្ណសារឲ្យបានគង់វង្សសម្រាប់មនុស្សជំនាន់ក្រោយ គឺពិតជាមានសារៈសំខាន់ណាស់។ ស្ថាប័នក៏គួរតែផ្តល់នូវការប្រើប្រាស់បណ្ណសារយ៉ាងទូលំទូលាយ ប៉ុន្តែប្រកបដោយសុវត្ថិភាពខ្ពស់ដល់ប្រជាជនទូទៅ ដើម្បីធ្វើការសិក្សាស្រាវជ្រាវនៅឯស្ថាប័ននោះ។ មួយវិញទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា ឬស្ថាប័នណាមួយដែលនឹងថែរក្សាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែវិនិយោគទៅលើផ្នែកបច្ចេកវិទ្យា ដើម្បីអនុញ្ញាតឲ្យសាធារណជន និងភាគីពាក់ព័ន្ធដទៃទៀតនៅទូទាំងពិភពលោក អាចប្រើប្រាស់បណ្ណសារនេះប្រកបដោយភាពងាយស្រួល។

### របាយការណ៍នេះ ត្រូវបានរៀបចំតាមរចនាសម្ព័ន្ធដូចខាងក្រោម៖

- **ផ្នែកទី ១** បង្ហាញអំពីកម្មវត្ថុ វិសាលភាព ដែនកំណត់ និងសារៈសំខាន់របស់ការសិក្សាស្ទង់មតិ។
- **ផ្នែកទី ២** ពិពណ៌នាអំពីវិធីសាស្ត្រស្រាវជ្រាវនៃការសិក្សាស្ទង់មតិនេះ។
- **ផ្នែកទី ៣** បង្ហាញអំពីលទ្ធផលស្រាវជ្រាវ និងការវិភាគលើការសិក្សាស្ទង់មតិ។
- **ផ្នែកទី ៤** បង្ហាញអំពីសេចក្តីសន្និដ្ឋាននានាដោយផ្អែកលើលទ្ធផលសំខាន់ៗនៃការស្រាវជ្រាវ។

ជាចុងក្រោយ ព័ត៌មានលម្អិតបន្ថែម ត្រូវបានផ្តល់ជូននៅក្នុងតារាង និងគំនូសតាង ដែលមាននៅក្នុងឧបសម្ព័ន្ធ។

# តារាងមាតិកា


ការបដិសេធទទួលខុសត្រូវ ..... ២
សេចក្តីថ្លែងអំណរគុណ ..... ៣
សេចក្តីសង្ខេប ..... ៤
តារាងមាតិកា ..... ៦
បញ្ជីគំនូសតារាង ..... ៧
បញ្ជីតារាង ..... ៨
ពាក្យកាត់ ..... ៩

**/// ១ /// គោលបំណង វិសាលភាព និងដែនកំណត់នៃការសិក្សាស្ទង់មតិ ..... ១១**
/// ១.១ /// គោលបំណងនៃការសិក្សាស្ទង់មតិ ..... ១១
/// ១.២ /// វិសាលភាព និង ដែនកំណត់នៃការសិក្សាស្ទង់មតិ ..... ១១

**/// ២ /// វិធីសាស្ត្រស្រាវជ្រាវ ..... ១៥**
/// ២.១ /// វិធីសាស្ត្របែបបរិមាណ និងគុណភាព ..... 15
/// ២.២ /// ក្រុមគោលដៅ និងការជ្រើសរើសសំណាក ..... 15
២.២.១. ប្រជាជនទូទៅ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ..... 16
២.២.២. អតីតកម្មាភិបាលខ្មែរក្រហម ..... 16
២.២.៣. និស្សិត សាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ ..... 17
២.២.៤. អ្នកផ្តល់ព័ត៌មានសំខាន់ៗ (Key Informant) ..... 17

**/// ៣ /// លទ្ធផលការស្រាវជ្រាវ និងការវិភាគ ..... ២១**
/// ៣.១ /// លទ្ធផលនៃការស្ទង់មតិ ( សំណាកជាក់ស្តែង ) ..... ២១
/// ៣.២ /// ស្ថានភាពប្រជាសាស្ត្រសង្គម និងស្ថានភាពសេដ្ឋកិច្ចសង្គម ..... ២៤
/// ៣.៣ /// ការទំនាក់ទំនង និងការចូលរួម ..... ២៩
/// ៣.៤ /// បទពិសោធន៍ពីរបបខ្មែរក្រហម ..... ៣២
/// ៣.៥ /// ការយល់ដឹង និងចំណេះដឹងអំពីអ.វ.ត.ក ..... ៣៨
/// ៣.៦ /// ការរក្សាទុកប្រវត្តិសាស្ត្រ និងកំណត់ត្រារបស់ អ.វ.ត.ក ..... ៤៣
/// ៣.៧ /// ចំណេះដឹងអំពី កម្មវិធី ព្រឹត្តិការណ៍ និងសកម្មភាពរបស់មជ្ឍមណ្ឌលឯកសារកម្ពុជា ..... ៥៨

**/// សេចក្តីសន្និដ្ឋាន /// ..... ៦៧**
**/// ឧបសម្ព័ន្ធ /// ..... ៧៣**




# បញ្ជីគំនូសតារាង


គំនូសតាងទី ១៖ ការចាត់ថ្នាក់ទីប្រជុំជន-ទីជនបទ តាមភេទ ..... ២៤
គំនូសតាងទី ២៖ ការចាត់ថ្នាក់ក្រុមអ្នកផ្តល់បទសម្ភាសន៍ តាមភេទ ..... ២៤
គំនូសតាងទី ៣៖ ការចាត់ថ្នាក់អាយុទៅតាមភេទ ..... ២៥
គំនូសតាងទី ៤៖ ស្ថានភាពមុខរបរតាមភេទ ..... ២៥
គំនូសតាងទី ៥៖ ស្ថានភាពមុខរបរចាត់ថ្នាក់ទៅតាមក្រុម ..... ២៦
គំនូសតាងទី ៦៖ ចាត់ថ្នាក់សាសនាតាមភេទ ..... ២៦
គំនូសតាងទី ៧៖ ការចាត់ថ្នាក់កម្រិតការសិក្សាអប់រំតាមភេទ ..... ២៧
គំនូសតាងទី ៨៖ ការចាត់ថ្នាក់កម្រិតការសិក្សាអប់រំតាមក្រុម ..... ២៨
គំនូសតាងទី ៩៖ ការចាត់ថ្នាក់ចំណូលទៅតាមភេទ ..... ២៨
គំនូសតាងទី ១០៖ ការចាត់ថ្នាក់ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតទៅតាមភេទ និងសំណាក ..... ២៩
គំនូសតាងទី ១១៖ ភាពញឹកញាប់នៃការប្រើប្រាស់បណ្តាញសង្គម ចាត់ថ្នាក់តាមភេទ និងតាមសំណាក ..... ២៩
គំនូសតាងទី ១២៖ ភាពញឹកញាប់នៃការមើលទូរទស្សន៍ ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក ..... ៣០
គំនូសតាងទី ១៣៖ ភាពញឹកញាប់នៃការស្តាប់វិទ្យុ ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក ..... ៣០
គំនូសតាងទី ១៤៖ ប្រភពព័ត៌មានដែលគួរឲ្យជឿទុកចិត្តបំផុតនៃព្រឹត្តិការណ៍នានានៅក្នុងប្រទេសកម្ពុជា ..... ៣១
គំនូសតាងទី ១៥៖ អ្នករស់នៅឆ្លងកាត់របបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក ..... ៣២
គំនូសតាងទី ១៦៖ ប្រភេទនៃអំពើហិង្សា ឬការធ្វើទារុណកម្មដែលធ្លាប់មានបទពិសោធន៍ ឆ្លងកាត់របបខ្មែរក្រហមផ្ទាល់ ..... ៣៣
គំនូសតាងទី ១៧៖ អារម្មណ៍នៃអ្នកផ្តល់បទសម្ភាសន៍ចំពោះរបបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមភេទ ..... ៣៤
គំនូសតាងទី ១៨៖ អារម្មណ៍អ្នកផ្តល់បទសម្ភាសន៍ចំពោះរបបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមសំណាក ..... ៣៥
គំនូសតាងទី ១៩៖ ប្រភពដែលអ្នករៀនសូត្រអំពីរបបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក ..... ៣៦
គំនូសតាងទី ២០៖ តើអ្នកធ្លាប់ឮឈ្មោះស្ថាប័នទាំងនេះដែរឬទេ ? ..... ៣៨
គំនូសតាងទី ២១៖ តើអ្នកធ្លាប់ឮឈ្មោះអ.វ.ត.កដែរឬទេ ? ..... ៣៩
គំនូសតាងទី ២២៖ តើអ្នកធ្លាប់ឮឈ្មោះសាលាក្តីខ្មែរក្រហមដែរឬទេ ? ..... ៣៩
គំនូសតាងទី ២៣៖ តើអ.វ.ត.ក/សាលាក្តីខ្មែរក្រហមមានតួនាទីអ្វីខ្លះ ? ( ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក ) ..... ៤០
គំនូសតាងទី ២៤៖ ប្រភេទនៃ អ.វ.ត.ក ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក ..... ៤២
គំនូសតាងទី ២៥៖ តើអ្នកគិតថានរណាជាម្ចាស់ជំនួយផ្តត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់អ.វ.ត.ក ( ចាត់ថ្នាក់ទៅតាមភេទ និងសំណាក ) ..... ៤៣
គំនូសតាងទី ២៦៖ ការចាត់ថ្នាក់ពីការស្គាល់ឈ្មោះស្ថាប័ននានាទៅតាមភេទ ..... ៤៤
គំនូសតាងទី ២៧៖ ការស្គាល់ឈ្មោះស្ថាប័ននានា នៅតាមចំណាត់ថ្នាក់របស់សំណាក ..... ៤៥
គំនូសតាងទី ២៨៖ ការស្គាល់ឈ្មោះស្ថាប័ននានា នៅតាមកម្រិតការសិក្សាអប់រំ ..... ៤៧
គំនូសតាងទី ២៩៖ កម្រិតនៃការយល់ស្របចាត់ថ្នាក់ទៅតាមភេទ សំណាក និងកម្រិតការសិក្សាអប់រំ ..... ៥០
គំនូសតាងទី ៣០៖ លក្ខណៈសម្បត្តិនៃស្ថាប័នដែលសក្តិសមនឹងរក្សាបណ្ណសាររបស់អ.វ.ត.ក ចាត់ថ្នាក់ទៅតាមភេទ ..... ៥១
គំនូសតាងទី ៣១ ៖ លក្ខណៈសម្បត្តិនៃស្ថាប័នដែលសក្តិសមនឹងរក្សាបណ្ណសាររបស់អ.វ.ត.ក ចាត់ថ្នាក់ទៅតាមសំណាក ..... ៥២
គំនូសតាងទី ៣២៖ លក្ខណៈសម្បត្តិនៃស្ថាប័នដែលសមនឹងរក្សាបណ្ណសារ ( សម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ ) ..... ៥៣

គំនូសតាងទី ៣៣៖ ស្ថាប័នដែលអ្នកចង់ឲ្យរក្សាទុកបណ្ណសាររបស់អ.វ.ត.ក (ចាត់ថ្នាក់តាមភេទ) ..... ៥៤
គំនូសតាងទី ៣៤៖ ស្ថាប័នដែលអ្នកចង់ឲ្យរក្សាទុកបណ្ណសាររបស់អ.វ.ត.ក (ចាត់ថ្នាក់តាមសំណាក) ..... ៥៥
គំនូសតាងទី ៣៥៖ តើបណ្ណសារនៃអ.វ.ត.កគួរតែត្រូវបានរក្សាទុកនៅឯណា? (សម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ) ..... ៥៦
គំនូសតាងទី ៣៦៖ ការចូលរួមក្នុងសកម្មភាព/ព្រឹត្តិការណ៍រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ និងសំណាក) ..... ៥៨
គំនូសតាងទី ៣៧៖ ប្រសិនបើអ្នកធ្លាប់បានចូលរួមព្រឹត្តិការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា តើអ្នកធ្លាប់ចូលរួមព្រឹត្តិការណ៍ណាមួយ (ចាត់ថ្នាក់តាមភេទ និងសំណាក)? ..... ៥៩
គំនូសតាងទី ៣៨៖ កម្រិតនៃការយល់ស្របទៅលើប្រយោគដែលទាក់ទងនឹងព្រឹត្តិការណ៍ដែលអ្នកបានចូលរួម (ចាត់ថ្នាក់តាមភេទ និងតាមសំណាក) ..... ៥៩
គំនូសតាងទី ៣៩៖ តើអ្នកធ្លាប់ទៅការិយាល័យកណ្តាលនៅភ្នំពេញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? (ចាត់ថ្នាក់តាមភេទ និងតាមសំណាក) ..... ៦០
គំនូសតាងទី ៤០៖ ប្រសិនបើអ្នកធ្លាប់ទៅការិយាល័យកណ្តាលនៅភ្នំពេញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, តើអ្នកទៅក្នុងគោលបំណងអ្វី? (ចាត់ថ្នាក់តាមភេទ និងតាមសំណាក) ..... ៦០
គំនូសតាងទី ៤១៖ កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ថ្នាក់ទៅតាមភេទ ..... ៦២
គំនូសតាងទី ៤២៖ កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ថ្នាក់ទៅតាមសំណាក ..... ៦៣
គំនូសតាងទី៤៣៖ ការស្គាល់ស្ថាប័នផ្សេងទៀតដែលធ្វើការមានគោលដៅស្រដៀងគ្នាទៅនឹងគោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទៅតាមភេទ និងតាមសំណាក ..... ៦៤

# បញ្ជីតារាង

តារាងទី ១ ៖ សំណាកគោលដៅសម្រាប់ប្រជាជនទូទៅ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈការចាត់ថ្នាក់ទីប្រជុំជន ទីជនបទ និងភេទ ..... ១៦
តារាងទី ២ ៖ សំណាក និស្សិត សាស្ត្រាចារ្យ ..... ១៧
តារាងទី ៣ ៖ សំណាកសម្រាប់អ្នកផ្តល់ព័ត៌មានសំខាន់ៗ ..... ១៧
តារាងទី ៤៖ ការសង្ខេបអំពីសំណាកនៃក្រុមគោលដៅនីមួយៗ ..... ១៧
តារាងទី ៥ ៖ ចំនួនអ្នកផ្តល់បទសម្ភាសន៍ជាក់ស្តែងតាមខេត្តនានា ..... ២១
តារាងទី ៦៖ ការសង្ខេបចំនួនសំណាកគោលដៅ និងចំនួនសំណាកដែលបានសម្ភាសជាក់ស្តែងតាមក្រុម ..... ២១
តារាងទី ៧៖ ព័ត៌មានលម្អិតអំពីសំណាកគោលដៅ និងសំណាកជាក់ស្តែងតាមក្រុមនីមួយៗ ..... ២២
តារាងទី ៨៖ ព័ត៌មានលម្អិតនៃសំណាកគោលដៅធៀបទៅនឹងសំណាកជាក់ស្តែងសម្រាប់ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ..... ២៣
តារាងទី ៩៖ កម្រិតនៃការយល់ស្របជាមធ្យមចំពោះលក្ខណៈសម្បត្តិរបស់ស្ថាប័ននីមួយៗ ..... ៤៨
តារាងទី ១០៖ កម្រិតនៃការយល់ស្របជាមធ្យមចំពោះការរក្សាបណ្ណសាររបស់ អ.វ.ត.ក ..... ៤៩
តារាងទី ១១៖ ពិន្ទុជាមធ្យមលើលក្ខណៈសម្បត្តិរបស់ស្ថាប័នដែលរក្សាទុកបណ្ណសាររបស់អ.វ.ត.ក ..... ៥០
តារាងទី ១២៖ ពិន្ទុជាមធ្យមនៃកម្រិតយល់ស្របទៅលើមជ្ឈមណ្ឌលឯកសារកម្ពុជា ..... ៦១
តារាងទី ១៣៖ ការចាត់ថ្នាក់សំណាកប្រជាជនទូទៅ/សាធារណៈ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមខេត្ត ..... ៦៩



# ពាក្យកាត់

| | |
|---|---|
| BDLINK | Business Development Link (Cambodia) Co., Ltd |
| CSOs | Civil Society Organizations |
| DC-Cam | Documentation Center of Cambodia |
| DKa | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia |
| KR | Khmer Rouge |
| LDC | Legal Documentation Centre |
| Max | Maximum |
| Min | Minimum |
| MoEYS | Ministry of Education, Youth and Sports |
| MoJ | Ministry of Justice |
| MoP | Ministry of Planning |
| NAC | National Archives of Cambodia |
| PPS | Probability Proportional to Size |
| RAC | Royal Academy of Cambodia |
| RULE | Royal University of Law and Economics |
| Std. Dev. | Standard Deviation |
| UNESCO | The United Nations Educational, Scientific and Cultural Organization |
| USAID | The United States Agency for International Development |



**សុន សេន** ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុល ពត ប្រចាំការនៅភ្នំ១០០១ ខេត្តព្រះវិហារ ប្រហែលដើមឆ្នាំ១៩៨០។ នៅឆ្នាំ១៩៩៧ សុន សេន ត្រូវបានធ្វើឃាតនៅក្នុងស្រុកអន្លង់វែង។ ទីតាំងបូជាសពរបស់ សុន សេន ត្រូវបានថែរក្សាទុកសព្វថ្ងៃនេះ។ ស្ថិតនៅចម្ងាយ៨.៩គីឡូម៉ែត្រពីរង្វង់មូល ស្រុកវាលវែង ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ ដែលត្រូវបានសម្លាប់នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ ស្ថិតនៅក្នុងភូមិស្រះឈូក ឃុំត្រពាំងវែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ទីតាំងនេះស្ថិតនៅលើផ្ទៃដី០.០៦២ហិចតា។ នៅលើទីតាំងនេះ សាកសព សុន សេន ព្រមទាំងសមាជិកគ្រួសារចំនួន១០នាក់ទៀត (រួមមាន និរសារ អ្នកបើកឡាន និងកូនស្រីពីរនាក់) ត្រូវបានបូជាបន្ទាប់ពីត្រូវបានបាញ់សម្លាប់។ កូនស្រីរបស់ សុន សេន ពីរនាក់ត្រូវបានអូសទៅកាន់ប្រឡាយ ហើយរំលោភដោយ ឈ្មោះ រ៉ន ដែលត្រូវជាកូនប្រសាររបស់ សារឿន (ហៅតា០៥)។ ស្ត្រីទាំងពីរនាក់ត្រូវបានកាត់ក្បាលយ៉ាងសាហាវ។ ក្រោយមក តាម៉ុក និងបក្ខពួកបានប្រមូលសាកសពពីបក្ខពួករបស់ ប៉ុល ពត ដែលបានប្រព្រឹត្តអំពីឃាតកម្មនេះ ហើយបូជាសាកសពទាំងអស់រួមគ្នា។ តាម៉ុក បានបញ្ជាឲ្យថតរូបនៃការសម្លាប់នេះ ហើយបង្ហាញទៅអ្នកភូមិអន្លង់វែង។ អ្នកភូមិទាំងអស់មានការរន្ធត់នៅពេលដឹងថា ប៉ុល ពត បានបញ្ជាឲ្យមានការសម្លាប់មេដឹកនាំជាន់ខ្ពស់មួយរូប ដែលធ្លាប់បានតស៊ូជាមួយគ្នា។ កំហឹងកើតមានឡើង ហើយបានបែងចែកជាពីក្រុម មួយក្រុមដឹកនាំដោយ ប៉ុល ពត និងមួយក្រុមទៀតដឹកនាំដោយ តាម៉ុក។ ក្រុមទាំងពីរនេះ ធ្វើការវាយប្រយុទ្ធគ្នាអស់រយៈពេល៥ថ្ងៃ។ បន្ទាប់មក តាម៉ុក ប្រកាសទៅចំពោះក្រុមដែលប្រឆាំងថា "សូមវិលត្រឡប់មកផ្ទះរបស់អ្នកវិញ ហើយទម្លាក់អាវុធចុះ ពីព្រោះយើងមានគ្នាតិចណាស់ ដូច្នេះយើងត្រូវតែរួបរួមសាមគ្គីគ្នា"។ ក្រោយមក ក្រុមដែលប្រឆាំងបានទម្លាក់អាវុធចុះហើយប្រគល់ខ្លួន។ តាម៉ុក បានចាប់ខ្លួនមេបញ្ជាការមួយចំនួនមានដូចជា សារឿន (ហៅតា០៥), សាន, យ៉ាន, ងួន, ខេមរា និង សេន។ តាម៉ុក បានឃុំខ្លួនអ្នកទាំងនោះក្នុងគុកដែក ដែលស្ថិតនៅក្នុងផ្ទះ តាម៉ុក ក្នុងតំបន់អូរជីក។ តាម៉ុក បានបញ្ជាឲ្យបក្ខពួករបស់ខ្លួន សាងសង់ផ្ទះតូចមួយសម្រាប់ ប៉ុល ពត ដែលរស់នៅទីនោះដូចជាមនុស្សសាមញ្ញធម្មតា។

*រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

# /// ១ ///
# គោលបំណង វិសាលភាព និងដែនកំណត់នៃការសិក្សាស្ទង់មតិ

**បង្ហាញអំពីកម្មវត្ថុ វិសាលភាព ដែនកំណត់ និងសារៈសំខាន់របស់ការសិក្សាស្ទង់មតិ។**

## /// ១.១ ///
## គោលបំណងនៃការសិក្សាស្ទង់មតិ

ការរៀបចំគ្រប់គ្រងបណ្ណសារ គឺមិនត្រឹមតែជាបញ្ហាមួយដ៏មានសារៈសំខាន់ចំពោះកេរដំណែលជានិរន្តរ៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) តែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងចំពោះការថែរក្សានិងការពារសុវត្ថិភាពនៃកំណត់ត្រាប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយទៀតផង។ អ្នកសង្កេតការណ៍នៅខាងក្រៅជាច្រើន បានសម្តែងការព្រួយបារម្ភអំពីភាពត្រឹមត្រូវនៃប្រវត្តិសាស្ត្រ បូរណភាព និងសុវត្ថិភាពនៃកំណត់ត្រារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រសិនបើកំណត់ត្រាទាំងនោះត្រូវបានផ្ទេរនិងគ្រប់គ្រងដោយភាគីមួយដែលងាយទទួលរងឥទ្ធិពលបុគ្គលឬនយោបាយ ដែលនឹងអាចបណ្តាលឲ្យខ្លឹមសារនៃបណ្ណសារទាំងនោះផ្លាស់ប្តូរ ត្រូវបានកែសម្រួលខុសភាពដើម ឬត្រូវបានកម្ទេចចោល។ គោលបំណងនៃការសិក្សានេះ គឺធ្វើឡើងដើម្បីស្ទង់មតិ និងឥរិយាបថរបស់ប្រជាជនកម្ពុជា ទាក់ទងនឹងការរៀបចំនិងការថែរក្សាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីឱ្យព័ត៌មានទាំងនេះអាចដើរតួនាទីជាគន្លឹះក្នុងការសម្រេចចិត្តថាតើកំណត់ត្រាប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់ទាំងនោះ នឹងត្រូវបានថែរក្សាទុកនិងការពារសុវត្ថិភាពនៅកន្លែងណា និងដោយរបៀបណា។ លើសពីនេះទៅទៀត ការសិក្សាស្ទង់មតិនេះបានផ្តល់ជាឱកាសជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបង្កើតផែនការនិងយុទ្ធសាស្ត្រការងារសម្រាប់រយៈពេលវែង ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវក៏ដូចជាផ្សព្វផ្សាយអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងការងាររបស់មជ្ឈមណ្ឌលនេះ ដែលមានភាពជិតស្និទ្ធទៅនឹងការរៀបចំគ្រប់គ្រងនិងថែរក្សាបណ្ណសារ។

## /// ១.២ ///
## វិសាលភាព និង ដែនកំណត់នៃការសិក្សាស្ទង់មតិ

ការសិក្សាស្ទង់មតិនេះ ផ្តល់ការយល់ដឹងដ៏មានតម្លៃអំពីការយល់ឃើញរបស់ប្រជាជនកម្ពុជាទាក់ទងនឹងការរៀបចំគ្រប់គ្រងបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងឯកសារប្រវត្តិសាស្ត្រសំខាន់ដទៃៗទៀត ដែលបន្សល់ទុកពីរបបខ្មែរក្រហម។

## គោលបំណង វិសាលភាព និងដែនកំណត់នៃការសិក្សាស្ទង់មតិ



*រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

រូបទីមួយខាងឆ្វេង៖ នួន ជា គឺជាប្រធានសភាតំណាងប្រជាជន និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ រូបទីពីរខាងឆ្វេង៖ វ៉ន វ៉េត គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ រូបទីបីខាងឆ្វេង៖ ខៀវ សំផន គឺជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ រូបទីបួនខាងឆ្វេង៖ តាម៉ុក គឺជាលេខាភូមិភាគនិរតី។ រូបទីប្រាំខាងឆ្វេង (អង្គុយខាងក្រោយ តាម៉ុក)៖ ចេង អន គឺជាប្រធានគណៈលេខាក្រសួង ឧស្សាហកម្ម។ រូបទីមួយខាងស្តាំ៖ កែ ពក គឺជាលេខាភូមិភាគឧត្តរ (ភូមិភាគកណ្តាល)។ រូបទីពីរខាងស្តាំ៖ ជូ ជេត គឺជាលេខាភូមិភាគបស្ចឹម។ រូបទីបីខាងស្តាំ៖ អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការ បរទេស។

*(រូបថតប្រហែលក្នុងឆ្នាំ ១៩៧៧)*

ទោះជាយ៉ាងណាក៏ដោយ បុគ្គលគួរតែយល់ដឹងអំពីវិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះ ដើម្បីជាជំនួយក្នុងការបកស្រាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងកំណត់ផ្នែកណាមួយសម្រាប់ការស្រាវជ្រាវបន្ថែម។ ដែនកំណត់នៃការសិក្សាស្ទង់មតិនេះរួមបញ្ចូល៖

(១) វិសាលភាពគ្របដណ្តប់នៃការសិក្សាស្ទង់មតិ ត្រូវបានកំណត់នៅត្រឹមខេត្តដែលមានប្រជាជនច្រើនចំនួន៤ និងទីក្រុងភ្នំពេញ ដោយមានការសន្មតថាសំណាកនេះអាចតំណាងឱ្យប្រជាជនស្ទើរតែទូទាំងប្រទេសបាន។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលស្រាវជ្រាវនេះមិនបានឆ្លុះបញ្ចាំងពេញលេញអំពីទស្សនៈប្រជាជននៅតំបន់ដទៃៗទៀត ដែលរួមមានតំបន់ភាគឦសាន និងពាយ័ព្យនោះទេ។

(២) យើងអាចសន្មតបានថា អ្នកចូលរួមមួយចំនួនប្រហែលជាមានការស្ទាក់ស្ទើរក្នុងការចូលរួមឱ្យបានពេញលេញនិងដោយចំហនៅក្នុងការសិក្សានេះ ដោយសារតែភាពរសើបនៃបញ្ហានេះ។ ក្រុមអ្នកស្រាវ ជ្រាវបានពិចារណាលើបញ្ហានេះ នៅពេលបង្កើតនិងអនុវត្តការស្ទង់មតិ។

តាម៉ុក ហៅ តា១៥ ហៅ ងួន កង មានឈ្មោះដើម ឈិត ជឿន ឬ អ៊ុង ជឿន កើតឆ្នាំ១៩២៦ នៅភូមិប្រគាប ឃុំត្រពាំងធំត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ គឺជាកូនច្បងក្នុងចំណោមបងប្អូន៧នាក់ ដែលមានឪពុកពុកឈ្មោះ អ៊ុង ប្រាក់ និងម្តាយឈ្មោះ អ៊ុក សុច។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ តាម៉ុក បានចូលបម្រើក្នុងចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងនឹងជប៉ុន និងត្រូវបានចាត់តាំងជាប្រធានចលនាខ្មែរឥស្សរៈស្រុកត្រាំកក់នៅឆ្នាំ១៩៤៩។ នៅឆ្នាំ១៩៥៤ នៅពេលដែលប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំង តាម៉ុក បានបួសជាសង្ឃនៅក្នុងខេត្តកំពង់ស្ពឺ និងបានបន្តសកម្មភាពនយោបាយដោយសម្ងាត់។ ក្នុងឆ្នាំ១៩៦៦ តាម៉ុក មានតួនាទីជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគនិរតី។ ក្នុងឆ្នាំ១៩៧២ តាម៉ុក មានជាប់ទាក់ទងនឹងការបញ្ជាឲ្យមានការវាយប្រហារជាលើកដំបូងទៅលើវប្បធម៌ និងទំនៀមទម្លាប់របស់ជនជាតិចាមនៅក្នុងប្រទេសកម្ពុជា។ នៅខែមីនា ឆ្នាំ១៩៧៤ តាម៉ុក សហការជាមួយ កែ ពក បានដឹកនាំកម្លាំងចូលកាន់កាប់ក្រុងឧត្តុង្គ និងបានបង្ខំឲ្យប្រជាជនប្រមាណ២ម៉ឺននាក់ ជម្លៀសចេញទៅកាន់ទីជនបទ ជាកន្លែងដែលអ្នកជម្លៀសទាំងនោះត្រូវបានសម្លាប់និងបង្អត់អាហារ។ ពីឆ្នាំ១៩៧៥ដល់១៩៧៧ ក្នុងនាមជាលេខាភូមិភាគនិរតី តាម៉ុក ជាប់ទាក់ទងនឹងការសម្លាប់រង្គាលប្រជាជនកម្ពុជា រួមទាំងការសម្លាប់មនុស្សប្រមាណ៣ម៉ឺននាក់នក្នុងស្រុកអង្គរជ័យ។ នៅចុងឆ្នាំ១៩៧៨ តាម៉ុក បានទទួលបញ្ជាឲ្យកាន់កាប់ភូមិភាគពាយ័ព្យ ដើម្បីបោសសម្អាតខ្មាំងក្បត់អង្គការ។ ក្នុងឆ្នាំដដែល តាម៉ុក ត្រូវបានតែងតាំងជាអនុលេខាទីពីរនៃបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ តាម៉ុក បានភៀសខ្លួនទៅកាន់ភាគខាងលិចប្រទេស ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ហើយបានគ្រប់គ្រងកម្លាំងយោធានៅទីនោះរហូតដល់ពេលចាប់ខ្លួនដោយកងកម្លាំងរាជរដ្ឋាភិបាលនៅថ្ងៃទី៦ ខែមីនាឆ្នាំ១៩៩៩។ តាម៉ុក ត្រូវបញ្ជូនមកដាក់ក្នុងមន្ទីរឃុំឃាំងនៅភ្នំពេញ រហូតដល់ស្លាប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦។

*រូបថតដោយ៖ ដេម ដឺរ៉ាន (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*





The rice fields of former Khmer Rouge region 5 (Banteay Meanchey province)

*រូបថត៖ អ៊ូច មករា / បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

# /// ២ ///
# វិធីសាស្ត្រស្រាវជ្រាវ

**ផ្នែកនេះរៀបរាប់អំពីការរៀបចំ និងការដាក់ឱ្យប្រើប្រាស់នូវ ឧបករណ៍ក្នុងការស្ទង់មតិ និង លទ្ធផលដែលបានវិភាគរួច។**

## /// ២.១ ///
## វិធីសាស្ត្របែបបរិមាណ និងគុណភាព

ព័ត៌មានត្រូវបានប្រមូលមកពីអ្នកផ្តល់បទសម្ភាសតាមរយៈការសម្ភាសន៍ផ្ទាល់ ដោយប្រើប្រាស់កម្រងសំណួរដែលត្រូវបានរៀបចំឡើងសម្រាប់ការសម្ភាសន៍នេះ។ ការផ្តោតសំខាន់របស់កម្រងសំណួរ គឺការប្រមូលទិន្នន័យតាមបែបបរិមាណដែលអាចឱ្យយើងធ្វើការវិភាគរៀបតាមលំដាប់លំដោយ និងធ្វើការបង្ហាញជាលក្ខណៈប្រព័ន្ធ។ ការប្រមូលទិន្នន័យតាមបែបបរិមាណនេះនឹងត្រូវបំពេញបន្ថែមដោយសំណួរបើកតាមបែបគុណភាពមួយចំនួនដើម្បីស្វែងយល់បន្ថែម និងការពន្យល់ទាក់ទងទៅនឹងប្រធានបទជាក់លាក់មួយ។

ព័ត៌មានសំខាន់នៃបទសម្ភាសន៍ជាមួយអ្នកជំនាញក៏មានលក្ខណៈបែបគុណភាព។

## /// ២.២ ///
## ក្រុមគោលដៅ និងការជ្រើសរើសសំណាក

ការជ្រើសរើសសំណាកគឺផ្អែកលើទិន្នន័យរបស់ក្រសួងផែនការ (ឆ្នាំ២០១៥) និងរបាយការណ៍អប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០១៥ (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥) ដែលផ្តល់មូលនិធិដោយអង្គការយូនីស្កូ (UNECSO)។ ជាការកត់សម្គាល់ ខេត្តក្រុងចំនួន ៥ ដែលមានប្រជាជនច្រើនជាងគេត្រូវបានជ្រើសរើស រួមមាន រាជធានីភ្នំពេញ ខេត្តព្រៃវែង កណ្តាល បាត់ដំបង និងកំពង់ចាម ។

ដើម្បីយល់ដឹងឱ្យបានកាន់តែច្បាស់អំពីការយល់ឃើញជាសាធារណៈចំពោះបណ្ណសាររបស់ អ.វ.ត.ក អ្នកផ្តល់បទសម្ភាសន៍ ៥ក្រុម ត្រូវបានជ្រើសរើសដូចជា៖ ប្រជាជនទូទៅ អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម អតីតកម្មាភិបាលខ្មែរក្រហម និស្សិត និងសាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ និង អ្នកផ្តល់ព័ត៌មានសំខាន់ៗ ។

## ២.២.១. ប្រជាជនទូទៅ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ការជ្រើសរើសក្រុមគោលដៅតាមគោលបំណង ត្រូវបានប្រើដើម្បីកំណត់ចំនួនសំណាកសម្រាប់ក្រុមគោលដៅចំនួនពីរ៖ "ប្រជាជនទូទៅ" (មានអាយុចាប់ពី ១៨ ដល់ ៥៩ឆ្នាំ) និង " អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម " (អាយុចាប់ពី៦០ឆ្នាំឡើងទៅ)។ ចំនួននៃអ្នកផ្តល់បទសម្ភាសន៍គោលដៅសម្រាប់ខេត្តក្រុងនីមួយៗនៃខេត្តក្រុងទាំង៥ ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រសមាមាត្រប្រូបាប៊ីលីតេទៅនឹងទំហំ (Probability Proportional to Size - PPS) ដោយប្រើកម្រិតជឿជាក់ (confident interval) ៩៥% និងកម្រិតលម្អៀង (margin of error) ៥%។

ការបែងចែកទីប្រជុំជន និងទីជនបទគឺផ្អែកទៅលើរបាយការណ៍របស់ក្រសួងផែនការ និងទិន្នន័យឃុំសង្កាត់កម្ពុជា (ឆ្នាំ២០១៥)។ ការសិក្សានេះក៏បានប្រើប្រាស់ភាគរយនៃការបែងចែកទីប្រជុំជន និងទីជនបទ ដោយផ្អែកលើការស្ទង់មតិចន្លោះជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៣។ ដំណាក់កាលទីបីនៃការបែងចែកគឺការបែងចែកតាមភេទ (ប្រុស និងស្រី) ដោយផ្អែកទៅលើទិន្នន័យរបស់មន្ទីរផែនការថ្នាក់ខេត្ត (ឆ្នាំ២០១៥)។ ការបែងចែកសំណាកគោលដៅលម្អិតសម្រាប់ប្រជាជនទូទៅ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមត្រូវបានបង្ហាញនៅក្នុងតារាងទី១។

**តារាងទី ១ ៖ សំណាកគោលដៅសម្រាប់ប្រជាជនទូទៅ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈការចាត់ថ្នាក់ទីប្រជុំជន ទីជនបទ និងភេទ**

| ខេត្ត | ការចាត់ថ្នាក់ | ប្រជាជនទូទៅ | | អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម | | សរុប |
|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ប្រុស | ស្រី | |
| ភ្នំពេញ | ប្រជុំជន | ៤៩ | ៦៦ | ៤៩ | ៦៦ | ២៣០ |
| បាត់ដំបង | ប្រជុំជន | ១០ | ១០ | ១០ | ១០ | ៤០ |
| | ជនបទ | ៣៩ | ៤១ | ៣៩ | ៤១ | ១៦០ |
| ព្រៃវែង | ជនបទ | ៤៩ | ៥៣ | ៤៨ | ៥០ | ២០០ |
| កណ្ដាល | ប្រជុំជន | ១០ | ១០ | ៦ | ៨ | ៣៤ |
| | ជនបទ | ៣៧ | ៤៣ | ២៣ | ១៨ | ១២១ |
| កំពង់ចាម | ជនបទ | ៥០ | ៥១ | ៣៥ | ៤៨ | ១៨៥ |
| សរុប | | ២៤២ | ២៧៧ | ២១០ | ២៤១ | ៩៧០ |

ការសិក្សាក៏បានស្នើឡើងនូវតំបន់មួយចំនួនដោយផ្អែកលើទីប្រជុំជន ទីជនបទ និងការបែងចែកតាមយេនឌ័រក្នុងខេត្តនីមួយៗ និងការកំណត់ស្រុក/ខណ្ឌ ឃុំ/សង្កាត់សម្រាប់ការស្ទង់មតិដែលឆ្លុះបញ្ចាំងអំពីមតិនៃចំនួនប្រជាជនជាក់ស្តែង។ ឃុំនិងភូមិដែលមានប្រជាជនច្រើនត្រូវបានជ្រើសរើស។

## ២.២.២. អតីតកម្មាភិបាលខ្មែរក្រហម

សំណាកគោលដៅរួមបញ្ចូល " អតីតកម្មាភិបាលខ្មែរក្រហម " មួយចំនួន ដើម្បីប្រមូលទស្សនៈផ្សេងៗឱ្យបានច្រើនសម្រាប់ធ្វើឱ្យលទ្ធផលនៃការសិក្សាកាន់តែមានភាពគ្រប់ជ្រុងជ្រោយ។ បញ្ជីអតីតកម្មាភិបាលខ្មែរក្រហមត្រូវបានផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក្រុមហ៊ុនបណ្តាញអភិវឌ្ឍន៍ជំនួញបានជ្រើសរើសអតីតកម្មាភិបាលខ្មែរក្រហមជាក់ស្តែងដោយផ្អែកទៅលើទីលំនៅបច្ចុប្បន្នរបស់អ្នកទាំងនោះ នៅក្នុងឃុំ/សង្កាត់ និងស្រុក/ខណ្ឌដែលបានជ្រើសរើស។ អតីតកម្មាភិបាលខ្មែរក្រហមចំនួន៦០នាក់ ត្រូវបានជ្រើសរើសសម្រាប់ធ្វើបទសម្ភាសន៍នៅក្នុងខេត្តចំនួនពីរគឺ ខេត្តកណ្តាល និងខេត្តកំពង់ចាម។





## ២.២.៣. និស្សិត សាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ

ដើម្បីពង្រីកទស្សនៈសម្រាប់ការសិក្សា យើងក៏បានធ្វើការសម្ភាសនិស្សិត សាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យឯកជន និងសាធារណៈនានានៅក្រុងភ្នំពេញ។ ការជ្រើសរើសសំណាកមួយនេះ ក៏បានអនុវត្តទៅតាមវិធីសាស្ត្រជ្រើសរើសសំណាកដែលធ្វើការគណនាទិន្នន័យដែលមានស្រាប់សម្រាប់និស្សិតឧត្តមសិក្សាឆ្នាំ ២០១២-២០១៣ (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥) និងទិន្នន័យសាស្ត្រាចារ្យឆ្នាំ២០០៨-២០០៩ (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៩)។ តារាងខាងក្រោមបង្ហាញពីការបែងចែកសំណាក និស្សិត សាស្ត្រាចារ្យ។

**តារាងទី ២ ៖ សំណាក និស្សិត សាស្ត្រាចារ្យ**

| | ផ្នែកសិក្សាអប់រំ | | | |
|---|---|---|---|---|
| | និស្សិត | | សាស្ត្រាចារ្យសាកលវិទ្យាល័យ | |
| ខេត្ត ក្រុង | គ្រឹះស្ថានសាធារណៈ | គ្រឹះស្ថានឯកជន | គ្រឹះស្ថានសាធារណៈ | គ្រឹះស្ថានឯកជន |
| ភ្នំពេញ | ១៧៥ | ២១៥ | ១២ | ១៨ |
| សរុប | ៣៩០ | | ៣០ | |

## ២.២.៤. អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KEY INFORMANT)

លើសពីនេះទៅទៀត ចំនួននៃអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗត្រូវបានលើកឡើងសម្រាប់ការសម្ភាសដើម្បីផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីបញ្ហាទាក់ទងនឹងការរក្សាទុកបណ្ណសារ រួមទាំងបណ្ណាល័យផ្សេងៗ ព្រមទាំងបុគ្គលិកនៃ អ.វ.ត.ក។

**តារាងទី ៣ ៖ សំណាកសម្រាប់អ្នកផ្តល់ព័ត៌មានសំខាន់ៗ**

| បញ្ជីស្ថាប័ន/បុគ្គល | ចំនួនអ្នកផ្តល់បទសម្ភាសន៍ |
|---|---|
| បណ្ណាល័យជាតិ | ១ |
| ពុទ្ធសាសនបណ្ឌិត្យ | ១ |
| បណ្ណាល័យសម្តេចហ៊ុនសែន | ១ |
| បណ្ណាល័យព្រឹទ្ធសភា | ១ |
| សហគមន៍ស្រាវជ្រាវ | ៣ |
| បុគ្គលិកអ.វ.ត.ក (បច្ចុប្បន្ន និងអតីតបុគ្គលិក អ.វ.ត.ក) | ៥ |
| ដើមបណ្តឹងរដ្ឋប្បវេណី (ដើមបណ្តឹងរដ្ឋប្បវេណី១រូប ក្នុងខេត្តនីមួយៗ) | ៥ |
| តំណាងប្រទេសម្ចាស់ជំនួយ | ៤ |
| បណ្ណសារដ្ឋានជាតិ | ១ |
| សរុប | ២២ |

តារាងខាងក្រោមជាការសង្ខេបអំពីការបែងចែកសំណាកសម្រាប់សម្ភាសន៍។

តារាងទី ៤៖ ការសង្ខេបអំពីសំណាកនៃក្រុមគោលដៅនីមួយៗ

| ក្រុម | ចំនួនអ្នកផ្តល់បទសម្ភាសន៍ |
|---|---|
| សាធារណជន | ៥១៩ |
| អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម | ៤៥១ |
| អតីតកម្មាភិបាលខ្មែរក្រហម | ៦០ |
| និស្សិត | ៣៩០ |
| សាស្ត្រាចារ្យ | ៣០ |
| អ្នកផ្តល់ព័ត៌មានសំខាន់ៗ | ២២ |
| សរុប | ១,៤៧២ |


Victims participation.
*Photo by Chy Terith/Documentation Center of Cambodia Archives.*



Photo by Phat Piseth / Documentation Center of Cambodia Archives

# /// ៣ ///
# លទ្ធផលការស្រាវជ្រាវ និងការវិភាគ

ផ្នែកនេះបង្ហាញអំពីលទ្ធផលចម្បងៗ នៃការស្ទង់មតិ។

## /// ៣.១ ///
## លទ្ធផលនៃការស្ទង់មតិ (សំណាកជាក់ស្តែង)

មនុស្សសរុបចំនួន ១.៥៧៤ នាក់ ត្រូវបានសម្ភាសន៍សម្រាប់ការសិក្សានេះ ក្នុងនោះរួមមានអ្នកផ្តល់បទសម្ភាសន៍ចំនួន ១.៥៥៧ នាក់ និង អ្នកផ្តល់ព័ត៌មានសំខាន់ៗ ចំនួន១៧នាក់ថែមទៀត។

តារាងខាងក្រោមមានអ្នកផ្តល់បទសម្ភាសន៍១.៥៥៧នាក់ តាមខេត្តនានា (មិនរាប់បញ្ចូលអ្នកផ្តល់ព័ត៌មានសំខាន់ៗ ទាំង១៧នាក់ទេ)។

**តារាងទី ៥ ៖ ចំនួនអ្នកផ្តល់បទសម្ភាសន៍ជាក់ស្តែងតាមខេត្តនានា**

| ខេត្ត ក្រុង | ចំនួនអ្នកផ្តល់បទសម្ភាសន៍ |
|---|---|
| ភ្នំពេញ | ៧២០ |
| កណ្តាល | ២១២ |
| ព្រៃវែង | ២១១ |
| បាត់ដំបង | ២០៧ |
| កំពង់ចាម | ២០៧ |
| សរុប | ១,៥៥៧ |

តារាងខាងក្រោមជាការសង្ខេបអំពីសំណាកដែលបានស្នើឡើង និងសំណាកជាក់ស្តែងសម្រាប់ក្រុមនីមួយៗ

**តារាងទី ៦៖ ការសង្ខេបចំនួនសំណាកគោលដៅ និងចំនួនសំណាកដែលបានសម្ភាសជាក់ស្តែងតាមក្រុម**

| ក្រុម | ចំនួនសំណាកគោលដៅ | ចំនួនសំណាកបានសម្ភាសជាក់ស្តែង |
|---|---|---|
| ប្រជាជនទូទៅ | ៥១៩ | ៥៥០ |
| អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម | ៤៥១ | ៥១០ |
| អតីតកម្មាភិបាលខ្មែរក្រហម | ៦០ | ១៦ |
| និស្សិត | ៣៩០ | ៤៤៤ |
| សាស្ត្រាចារ្យ | ៣០ | ៣៧ |
| អ្នកផ្តល់ព័ត៌មានសំខាន់ៗ | ២២ | ១៧ |
| សរុប | ១,៤៧២ | ១,៥៧៤ |

សម្រាប់ក្រុមភាគច្រើន សំណាកសម្ភាសន៍បានជាក់ស្តែងមានចំនួនស្របទៅតាមចំនួនសំណាកគោលដៅ។ ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមគួរឲ្យកត់សម្គាល់ក្នុងការកំណត់ និងសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម។ បញ្ហាប្រឈមចម្បងគឺប្រធានភូមិ និងប្រជាជនក្នុងភូមិមិនស្គាល់ឈ្មោះអតីតកម្មាភិបាលខ្មែរក្រហមនោះទេ។ អតីតកម្មាភិបាលខ្មែរក្រហមខ្លះបានផ្លាស់ប្តូរទីលំនៅទៅកាន់ខេត្តផ្សេងទៀត និងអ្នកខ្លះទៀតបានទទួលមរណភាព។ ដូច្នេះហើយ មានតែអតីតកម្មាភិបាលខ្មែរក្រហមចំនួន១៦នាក់ប៉ុណ្ណោះត្រូវបានសម្ភាសន៍បើធៀបទៅនឹងសំណាកគោលដៅមានចំនួនដល់ទៅ៦០ ឯណោះ។ ដោយសារតែសំណាកអតីតកម្មាភិបាលខ្មែរក្រហមមានចំនួនតិច ក្រុមការងារស្រាវជ្រាវបានសម្រេចចិត្តមិនបង្ហាញលទ្ធផលសម្រាប់កម្មាភិបាលខ្មែរក្រហមទាំង១៦ដាច់ដោយឡែកទេ ប៉ុន្តែ ដាក់បញ្ចូលសំណាកនេះទៅក្នុងក្រុម «អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» វិញដោយសារតែអ្នកទាំងអស់នោះមានអាយុប្រហាក់ប្រហែលគ្នា។

ព័ត៌មានលម្អិតអំពីសំណាកគោលដៅ និងសំណាកជាក់ស្តែងនឹងត្រូវបង្ហាញនៅក្នុងតារាងខាងក្រោម។

**តារាងទី ៧៖ ព័ត៌មានលម្អិតអំពីសំណាកគោលដៅ និងសំណាកជាក់ស្តែងតាមក្រុមនីមួយៗ**

| | សំណាកគោលដៅ | | | សំណាកជាក់ស្តែង | | |
|---|---|---|---|---|---|---|
| ខេត្ត ក្រុង | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| **ប្រជាជនទូទៅ** | | | | | | |
| បាត់ដំបង | ៤៩ | ៥១ | ១០០ | ៥៣ | ៥២ | ១០៥ |
| កណ្តាល | ៤៧ | ៥៣ | ១០០ | ៤៨ | ៦០ | ១០៨ |
| កំពង់ចាម | ៥០ | ៥១ | ១០១ | ៤៨ | ៥៦ | ១០៤ |
| ភ្នំពេញ | ៤៩ | ៦៦ | ១១៥ | ៥២ | ៦៨ | ១២០ |
| ព្រៃវែង | ៤៩ | ៥៣ | ១០២ | ៥៤ | ៥៩ | ១១៣ |
| សរុប | ២៤៤ | ២៧៤ | ៥១៩ | ២៥៥ | ២៩៥ | ៥៥០ |
| **អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម** | | | | | | |
| បាត់ដំបង | ៥៩ | ៥១ | ១០០ | ៤៩ | ៥៣ | ១០២ |
| កណ្តាល | ២៩ | ២៦ | ៥៥ | ៤៦ | ៤៤ | ៩០ |
| កំពង់ចាម | ៣៥ | ៤៨ | ៨៣ | ៤៦ | ៥៥ | ១០១ |
| ភ្នំពេញ | ៤៩ | ៦៦ | ១១៥ | ៥២ | ៦៧ | ១១៩ |
| ព្រៃវែង | ៤៨ | ៥០ | ៩៨ | ៤៨ | ៥០ | ៩៨ |
| សរុប | ២១០ | ២៤១ | ៤៥១ | ២៤១ | ២៦៩ | ៥១០ |
| **អតីតកម្មាភិបាលខ្មែរក្រហម** | | | | | | |
| ខេត្ត ក្រុង | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| កណ្តាល | ១៨ | ២៧ | ៤៥ | ៦ | ៨ | ១៤ |
| កំពង់ចាម | ១០ | ៥ | ១៥ | ២ | ០ | ២ |
| សរុប | ២៨ | ៣២ | ៦០ | ៨ | ៨ | ១៦ |

| | សំណាកគោលដៅ | | | សំណាកជាក់ស្តែង | | |
|---|---|---|---|---|---|---|
| **និស្សិត សាស្ត្រាចារ្យ (រាជធានីភ្នំពេញ)** | | | | | | |
| តួនាទី | សាកលវិទ្យាល័យសាធារណៈ | សាកលវិទ្យាល័យឯកជន | សរុប | សាកលវិទ្យាល័យសាធារណៈ | សាកលវិទ្យាល័យឯកជន | សរុប |
| និស្សិត | ១៧៥ | ២១៥ | ៣៩០ | ២០០ | ២៤៤ | ៤៤៤ |
| សាស្ត្រាចារ្យ | ១២ | ១៨ | ៣០ | ២៥ | ១២ | ៣៧ |
| សរុប | ១៨៧ | ២៣៣ | ៤២០ | ២២៥ | ២៥៦ | ៤៨១ |

**តារាងទី ៨៖ ព័ត៌មានលម្អិតនៃសំណាកគោលដៅធៀបទៅនឹងសំណាកជាក់ស្តែងសម្រាប់ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ**

| បញ្ជីស្ថាប័ន/បុគ្គល | សំណាកគោលដៅ | សំណាកជាក់ស្តែង |
|---|---|---|
| បណ្ណាល័យជាតិ | ១ | ១ |
| ពុទ្ធសាសនបណ្ឌិត្យ | ១ | ១ |
| បណ្ណាល័យសម្តេចហ៊ុនសែន | ១ | ១ |
| បណ្ណាល័យព្រឹទ្ធសភា | ១ | ១ |
| សហគមន៍ស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល | ៣ | ២ |
| បុគ្គលិកអ.វ.ត.ក (បច្ចុប្បន្ន និងអតីតបុគ្គលិក) | ៥ | ០ |
| ដើមបណ្តឹងរដ្ឋប្បវេណី (ដើមបណ្តឹងរដ្ឋប្បវេណី១រូប ក្នុងខេត្តនីមួយៗ) | ៥ | ៥ |
| តំណាងម្ចាស់ជំនួយ | ៤ | ៥ |
| បណ្ណសារដ្ឋានជាតិ | ១ | ១ |
| សរុប | ២២ | ១៧ |

## /// ៣.២ ///
## ស្ថានភាពប្រជាសាស្ត្រសង្គម និងស្ថានភាពសេដ្ឋកិច្ចសង្គម

គំនូសតាងទី១ បង្ហាញចំនួនអ្នកផ្តល់បទសម្ភាសន៍ភេទប្រុស និងភេទស្រី នៅតាមទីប្រជុំជន និងទីជនបទ។ គំនូសតាងទី២ ពណ៌នាអំពីចំនួនអ្នកផ្តល់បទសម្ភាសន៍ភេទប្រុស និងភេទស្រីក្នុងចំណោមក្រុមសំណាកដូចជា៖ ប្រជាជនទូទៅ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងនិស្សិត សាស្ត្រាចារ្យ។

**គំនូសតាងទី ១៖ ការចាត់ថ្នាក់ទីប្រជុំជន-ទីជនបទ តាមភេទ**




**គំនូសតាងទី ២៖ ការចាត់ថ្នាក់ក្រុមអ្នកផ្តល់បទសម្ភាសន៍ តាមភេទ**




គំនូសតាងទី៣ បង្ហាញពីការចាត់ថ្នាក់អាយុរបស់អ្នកផ្តល់បទសម្ភាសន៍។ ទោះបីជាមានបុរស និងស្ត្រីនៅចម្រុះគ្នានៅក្នុងក្រុមអាយុនីមួយៗក៏ដោយ ក៏បុរសមានចំនួនច្រើនជាងស្ត្រីសម្រាប់អាយុចន្លោះពី ២០ទៅ៤៩ឆ្នាំ ហើយនៅអាយុផ្សេងទៀតមានស្ត្រីច្រើនជាងបុរស។ អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ ដែលសុទ្ធសឹងជាអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។

**គំនូសតាងទី ៣៖ ការចាត់ថ្នាក់អាយុទៅតាមភេទ**




គំនូសតាងទី៤ និងគំនូសតាងទី៥ ពណ៌នាអំពីស្ថានភាពមុខរបររបស់អ្នកផ្តល់បទសម្ភាសន៍ តាមក្រុមគោលដៅ និង តាមភេទ។ ស្ថានភាពមុខរបរចម្បងរបស់អ្នកផ្តល់បទសម្ភាសន៍មានដូចជា៖ និស្សិត អ្នកគ្មានការងារធ្វើ កសិករ និងប្រកបអាជីវកម្មផ្ទាល់ខ្លួន។

**គំនូសតាងទី ៤៖ ស្ថានភាពមុខរបរតាមភេទ**



ដូចបានគូសរំលេចនៅខាងក្រោម ប្រជាជនទូទៅភាគច្រើន រួមមានកសិករ អ្នកប្រកបរបររកស៊ី ឬនិយោជិត ចំណែកឯអ្នកនៅរស់រានមានជីវិតភាគច្រើនគ្មានការងារធ្វើ។

**គំនូសតាងទី ៥ ៖ ស្ថានភាពមុខរបរចាត់ថ្នាក់ទៅតាមក្រុម**




អ្នកផ្ដល់បទសម្ភាសន៍ភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយក្នុងនោះមានមួយចំនួនតូចជាអ្នកកាន់សាសនាអ៊ីស្លាម និងសាសនាគ្រិស្ត។

**គំនូសតាងទី ៦៖ ចាត់ថ្នាក់សាសនាតាមភេទ**






គំនូសតាងទី៧ និងគំនូសតាងទី៨ បង្ហាញអំពីកម្រិតការសិក្សាអប់រំរបស់អ្នកផ្ដល់បទសម្ភាសន៍ចាត់ថ្នាក់តាមភេទ និងចាត់ថ្នាក់តាមក្រុមនីមួយៗ។ នៅក្នុងការសិក្សានេះឃើញថាស្ត្រីមានកម្រិតការសិក្សាអប់រំទាបជាងបុរស។ វាហាក់គ្មានអ្វីចម្លែកនោះទេដែលក្រុមនិស្សិត សាស្ត្រាចារ្យ មានកម្រិតការសិក្សាអប់រំខ្ពស់បំផុតខណៈដែលអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមមានកម្រិតការសិក្សាអប់រំទាបបំផុត។

**គំនូសតាងទី ៧៖ ការចាត់ថ្នាក់កម្រិតការសិក្សាអប់រំតាមភេទ**




**គំនូសតាងទី ៨៖ ការចាត់ថ្នាក់កម្រិតការសិក្សាអប់រំតាមក្រុម**



ភាគច្រើននៃអ្នកផ្តល់បទសម្ភាសន៍មិនមានប្រាក់ចំណូលទេ (ភាគច្រើនគឺជានិស្សិត និងក្រុមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម)។ ក្នុងចំណោមអ្នកដែលមានប្រាក់ចំណូល ភាគច្រើនចំណូលដែលរកបានមានចំនួនក្រោម ២០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែឬចន្លោះពី ២០០ ទៅ ៤០០ដុល្លារសហរដ្ឋអាមេរិក។

**គំនូសតាងទី ៩៖ ការចាត់ថ្នាក់ចំណូលទៅតាមភេទ**






*Photo by Ouch Makara / Documentation Center of Cambodia Archives*





## /// ៣.៣ ///
## ការទំនាក់ទំនង និងការចូលរួម

ផ្នែកនេះផ្តល់នូវការយល់ដឹងអំពីការផ្សារភ្ជាប់ទំនាក់ទំនង និងការចូលរួមរបស់អ្នកផ្តល់បទសម្ភាសន៍តាមរយៈប្រភពព័ត៌មានផ្សេងៗ។ ផ្នែកនេះអាចជួយឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាអភិវឌ្ឍយុទ្ធសាស្ត្រ និងសកម្មភាពដើម្បីផ្សព្វផ្សាយព័ត៌មានដល់សាធារណជន និងអ្នកពាក់ព័ន្ធដទៃទៀត។

គំនូសតាងទី១០ បង្ហាញអំពីភាគរយនៃអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតទៅតាមចំណាត់ថ្នាក់ភេទ និងសំណាក។ វាបានបង្ហាញថាជាងពាក់កណ្តាលនៃអ្នកផ្តល់បទសម្ភាសន៍ប្រើប្រាស់ទូរស័ព្ទវៃឆ្លាត។ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតជាបុរសមានចំនួនច្រើនជាងអ្នកប្រើប្រាស់ជាស្ត្រី។ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតច្រើនបំផុតស្ថិតនៅក្នុងក្រុមនិស្សិត សាស្ត្រាចារ្យ ខណៈដែលភាគរយទាបបំផុតគឺនៅក្នុងក្រុមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេប្រសិនបើយើងមើលទៅតាមអាយុរបស់អ្នកដែលនៅក្នុងក្រុមទាំងពីរនេះ។

**គំនូសតាងទី ១០៖ ការចាត់ថ្នាក់ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតទៅតាមភេទ និងសំណាក**




ការប្រើប្រាស់បណ្តាញសង្គមរបស់អ្នកផ្តល់បទសម្ភាសន៍ឆ្លុះបញ្ចាំងក្នុងគំរូដូចអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតដែរ។ ដូចដែលបានបង្ហាញនៅក្នុងគំនូសតាងទី១១ មានជាងពាក់កណ្តាលនៃអ្នកផ្តល់បទសម្ភាសន៍ជាអ្នកប្រើប្រាស់បណ្តាញសង្គម។ ចំនួនអ្នកប្រើប្រាស់បណ្តាញសង្គមជាបុរសមានចំនួនច្រើនជាងអ្នកប្រើប្រាស់ជាស្ត្រី ហើយភាគច្រើននៃក្រុមនិស្សិត សាស្ត្រាចារ្យ ប្រើប្រាស់បណ្តាញសង្គមមានចំនួនច្រើនជាងប្រជាជនទូទៅ ឬអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

**គំនូសតាងទី ១១៖ ភាពញឹកញាប់នៃការប្រើប្រាស់បណ្តាញសង្គម ចាត់ថ្នាក់តាមភេទ និងតាមសំណាក**



ដូចដែលបានបង្ហាញនៅក្នុងគំនូសតាងទី១២ ច្រើនជាងពាក់កណ្តាលនៃអ្នកផ្តល់បទសម្ភាសន៍មើលទូរទស្សន៍ ដែលចំនួននេះមិនមានភាពខុសគ្នាគួរឲ្យកត់សម្គាល់នោះទេរវាងបុរស និងស្ត្រី។ ក្រុមនិស្សិត សាស្ត្រាចារ្យ មើលទូរទស្សន៍តិចជាងប្រជាជនទូទៅ ឬអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលអាចឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ទូរស័ព្ទវៃឆ្លាតរបស់និស្សិតសម្រាប់ការទទួលបានព័ត៌មាន និងការកម្សាន្តរបស់ខ្លួន។

**គំនូសតាងទី ១២៖ ភាពញឹកញាប់នៃការមើលទូរទស្សន៍ ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក**




គំនូសតាងទី១៣ បានបង្ហាញថាវិទ្យុមិនសូវពេញនិយមទេប្រសិនបើប្រៀបធៀបទៅនឹងទូរទស្សន៍ និងបណ្តាញសង្គម ទោះបីជាមានចំនួនច្រើនជាងពាក់កណ្តាលនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមស្តាប់វិទ្យុក៏ដោយ ។

**គំនូសតាងទី ១៣៖ ភាពញឹកញាប់នៃការស្តាប់វិទ្យុ ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក**








គំនូសតាងទី១៤ បង្ហាញអំពីប្រភពព័ត៌មានដែលអ្នកផ្តល់បទសម្ភាសន៍ពឹងផ្អែកជាចម្បង និងទុកចិត្ត សម្រាប់ទទួលព័ត៌មានអំពីហេតុការណ៍នានាដែលកើតឡើងនៅកម្ពុជា។ វាបានបង្ហាញថាទូរទស្សន៍នៅតែជាបណ្តាញទំនាក់ទំនងដែលគួរឲ្យទុកចិត្តបំផុតដើម្បីស្វែងយល់ពីរឿងរ៉ាវដែលកើតឡើងនៅប្រទេសកម្ពុជា បន្ទាប់ពីទូរទស្សន៍គឺបណ្តាញសង្គម និងវិទ្យុ។ កាសែត វេបសាយ និងបណ្តាញទំនាក់ទំនងដទៃទៀតគឺជាប្រភពដែលមិនសូវប្រើប្រាស់។

អ្នកផ្តល់បទសម្ភាសន៍ជានិស្សិត សាស្ត្រាចារ្យ ពឹងផ្អែកយ៉ាងខ្លាំងទៅលើបណ្តាញទំនាក់ទំនងសង្គម ខណៈដែលប្រជាជនទូទៅមានការពឹងផ្អែកភាគច្រើនទៅលើទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គម ហើយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានការពឹងផ្អែកភាគច្រើនទៅលើទូរទស្សន៍ និងវិទ្យុ។ មិនមានអ្វីខុសគ្នាគួរឲ្យកត់សម្គាល់ទេរវាងបុរស និងស្ត្រីនៅក្នុងផ្នែកនេះ។

**គំនូសតាងទី ១៤៖ ប្រភពព័ត៌មានដែលគួរឲ្យជឿទុកចិត្តបំផុតនៃព្រឹត្តិការណ៍នានានៅក្នុងប្រទេសកម្ពុជា**



លទ្ធផលខាងលើបានគូសបញ្ជាក់ថាទូរទស្សន៍ និងបណ្តាញសង្គម (រាប់បញ្ចូលទាំងទូរស័ព្ទវៃឆ្លាត) គឺជាប្រភពទំនាក់ទំនងសំខាន់បំផុត ទោះបីជាមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងសំណាកនៃក្រុមនីមួយៗដែលឆ្លុះបញ្ចាំងពីអាយុរបស់អ្នកទាំងនោះយ៉ាងណាក៏ដោយ។ ដូច្នេះ សកម្មភាពផ្សព្វផ្សាយព័ត៌មានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគួរតែពិចារណាទៅលើក្រុមគោលដៅ។ ជាឧទាហរណ៍ ប្រសិនបើចង់ឲ្យព័ត៌មានទៅដល់អ្នកដែលមានបទពិសោធន៍ក្នុងរបបខ្មែរក្រហម វិទ្យុ អាចជាឧបករណ៍មួយដែលមានប្រសិទ្ធភាព។ ទោះជាយ៉ាងណាការប្រើប្រាស់បណ្តាញសង្គមពិតជាមានប្រសិទ្ធភាពជាង ប្រសិនបើចង់ឲ្យព័ត៌មានទាំងនោះទៅដល់មនុស្សមានវ័យក្មេង ។ ការរួមបញ្ចូលគ្នារវាងប្រភពនៃប្រព័ន្ធផ្សព្វផ្សាយទាំងនោះពិតជាចាំបាច់ ប្រសិនបើចង់ឲ្យការផ្សព្វផ្សាយព័ត៌មានបានទូលំទូលាយទៅដល់ក្រុមគោលដៅប្រជាជនកម្ពុជាផ្សេងៗ។

## /// ៣.៤ ///
## បទពិសោធន៍ពីរបបខ្មែរក្រហម

ផ្នែកនេះបង្ហាញអំពីបទពិសោធន៍របស់អ្នកផ្តល់បទសម្ភាសន៍ពីរបបខ្មែរក្រហម និងលាតត្រដាងនូវអារម្មណ៍អភ័យទោស ការសងសឹក និងការស្អប់របស់ខ្លួនចំពោះរបបមួយនេះ។ ការស្វែងយល់អំពីអារម្មណ៍ទាំងនេះអាចផ្តល់នូវបរិបទបន្ថែមជុំវិញឥរិយាបថរបស់អ្នកផ្តល់បទសម្ភាសន៍ ចំពោះសារៈសំខាន់នៃការរក្សាទុកបណ្ណសាររបស់អ.វ.ត.ក។

សរុបមកមានអ្នកផ្តល់បទសម្ភាសន៍ជាងពាក់កណ្តាលជាអ្នកបានរស់នៅឆ្លងកាត់របបខ្មែរក្រហម។ វាមិនមានអ្វីប្លែកនោះទេ ដែលចម្លើយរបស់សំណួរនេះឆ្លុះបញ្ចាំងពីអាយុនៃសំណាកដូចជា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (អាយុចាប់ពី៦០ឆ្នាំឡើងទៅ) និងពាក់កណ្តាលជាប្រជាជនទូទៅ (អាយុចាប់ពី១៨ទៅ៥៩ឆ្នាំ) មានបទពិសោធន៍ឆ្លងកាត់របបនេះ ខណៈដែលមានតែ៥ភាគរយប៉ុណ្ណោះជាក្រុមនិស្សិតនិងសាស្ត្រាចារ្យ (មានសាស្ត្រាចារ្យមួយចំនួន) ធ្លាប់ឆ្លងកាត់របបនេះ។

**គំនូសតាងទី ១៥៖ អ្នករស់នៅឆ្លងកាត់របបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក**




គំនូសតាងទី១៦ បង្ហាញអំពីប្រភេទនៃអំពើហិង្សា ការធ្វើទារុណកម្ម និងការលំបាកដែលអ្នកចូលរួមមានបទពិសោធន៍ឆ្លងកាត់កំឡុងពេលរបបខ្មែរក្រហម។ នៅក្នុងចំណោមអ្នកដែលរស់នៅក្នុងរបបនេះមានរឿងរ៉ាវលំបាកៗជាច្រើនដែលខ្លួនជួបប្រទះដូចជា ភាពអត់ឃ្លាន ការបង្ខំឲ្យធ្វើការហួសកម្លាំង បង្ខំបំបែកពីក្រុមគ្រួសារ ការជម្លៀសដោយបង្ខំ និងការគំរាមសម្លាប់ជាដើម។





**គំនូសតាងទី ១៦៖ ប្រភេទនៃអំពើហិង្សា ឬការធ្វើទារុណកម្មដែលធ្លាប់មានបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមផ្ទាល់**




អ្នកផ្តល់បទសម្ភាសន៍ទាំងអស់ត្រូវបានសួរសំណួរអំពីអារម្មណ៍របស់ខ្លួនចំពោះរបបខ្មែរក្រហមដោយគ្រាន់តែឆ្លើយតបទៅនឹងប្រយោគដែលមានស្រាប់។ លទ្ធផលនឹងត្រូវបានបង្ហាញនៅគំនូសតាងទី១៧ (សម្រាប់អ្នកផ្តល់បទសម្ភាសន៍ទាំងអស់ បុរស និងស្ត្រី) និងគំនូសតាងទី១៨ (សម្រាប់និស្សិត សាស្ត្រាចារ្យ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាជនទូទៅ)។

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ អ្នកផ្តល់បទសម្ភាសន៍យល់ឃើញយ៉ាងមុតមាំថា អ្នកទទួលខុសត្រូវចំពោះរបបប្រល័យពូជសាសន៍ខ្មែរក្រហមគួរតែត្រូវបានផ្តន្ទាទោសតាមច្បាប់ (៩២ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍សរុប និងយ៉ាងហោចណាស់ ៨៨ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍ក្នុងក្រុមសំណាកនីមួយៗ)។ ខណៈនោះដែរ ក៏មានអ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានអភ័យទោស ឬត្រៀមខ្លួនរួចរាល់ដើម្បីអភ័យទោសឲ្យអ្នកទទួលខុសត្រូវរបបខ្មែរក្រហម (៥៧ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍សរុប ដែលមាន៥២ភាគរយនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង៦២ភាគរយនៃនិស្សិត សាស្ត្រាចារ្យ) ។

អ្នកផ្តល់បទសម្ភាសន៍បង្ហាញអារម្មណ៍ស្អប់ខ្ពើមយ៉ាងខ្លាំង ចំពោះអ្នកទទួលខុសត្រូវលើរាល់សកម្មភាពហិង្សានៅក្នុងរបបខ្មែរក្រហម (៨៧ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍សរុប ដែលមានយ៉ាងហោចណាស់មាន៨២ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍ក្នុងក្រុមសំណាកនីមួយៗ)។ ទោះជាយ៉ាងណាក៏ដោយ មានអ្នកផ្តល់បទសម្ភាសន៍មួយចំនួនមានអារម្មណ៍ថាចង់សងសឹក (២៣ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍សរុប ក្នុងនោះមាន១៧ភាគរយនៃក្រុមនិស្សិត សាស្ត្រាចារ្យ ២៧ភាគរយនៃក្រុមអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម) ។

លទ្ធផលទាំងនេះបញ្ជាក់ថា គ្រប់ផ្នែកទាំងអស់នៃសង្គមកម្ពុជា ដោយមិនគិតពីភេទ អាយុ ឬឋានៈមានអារម្មណ៍ស្រដៀងគ្នាចំពោះរបបខ្មែរក្រហម ។

## គំនូសតាងទី ១៧៖ អារម្មណ៍នៃអ្នកផ្តល់បទសម្ភាសន៍ចំពោះរបបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមភេទ






## គំនូសតាងទី ១៨៖ អារម្មណ៍អ្នកផ្តល់បទសម្ភាសន៍ចំពោះរបបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមសំណាក



អ្នកផ្តល់បទសម្ភាសន៍បានរៀនសូត្រពីរបបខ្មែរក្រហមតាមរយៈប្រភពខុសៗគ្នា អាស្រ័យទៅលើអាយុរបស់ខ្លួន។ ប្រភពទូទៅគឺបទពិសោធន៍ផ្ទាល់ខ្លួន (ជាពិសេសចំពោះអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម) សមាជិកគ្រួសារ (ជាពិសេសនិស្សិត សាស្ត្រាចារ្យ និងប្រជាជនទូទៅ) និងតាមរយៈសាលា (ជាពិសេសនិស្សិត សាស្ត្រាចារ្យ) ដូចដែលបានបង្ហាញនៅគំនូសតាងទី១៩។

**គំនូសតាងទី ១៩៖ ប្រភពដែលអ្នករៀនសូត្រអំពីរបបខ្មែរក្រហម ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក**






Youk Chhang and So Farina meeting with all Tuon and Hakim from across Cambodia
*Photo by Phat Piseth / Documentation Center of Cambodia Archives*

## /// ៣.៥ ///
## ការយល់ដឹង និងចំណេះដឹងអំពីអ.វ.ត.ក

គោលបំណងនៅក្នុងផ្នែកនេះបង្ហាញពីការយល់ដឹង និងចំណេះដឹងរបស់អ្នកផ្ដល់បទសម្ភាសន៍អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅកាត់ថាអ.វ.ត.ក។

លទ្ធផលនៅគំនូសតាងទី២០ បញ្ជាក់ថាមានតែ១៧ភាគរយនៃអ្នកផ្ដល់បទសម្ភាសន៍សរុបតែប៉ុណ្ណោះដែលមិនស្គាល់ទាំង អ.វ.ត.ក និងសាលាក្ដីខ្មែរក្រហម ចំណែកឯ៣៧ ភាគរយទៀត ស្គាល់ស្ថាប័នតែមួយក្នុងចំណោមស្ថាប័នទាំងពីរ និងមាន៤៦ភាគរយទៀតស្គាល់ស្ថាប័នទាំងពីរនេះ។

**គំនូសតាងទី ២០៖ តើអ្នកធ្លាប់ឮឈ្មោះស្ថាប័នទាំងនេះដែរឬទេ?**




ក្រាហ្វិកទាំងពីរខាងក្រោមនេះបង្ហាញអំពីភាគរយនៃអ្នកផ្ដល់បទសម្ភាសន៍ដែលធ្លាប់ឮឈ្មោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (គំនូសតាងទី២១) និងធ្លាប់ឮឈ្មោះសាលាក្ដីខ្មែរក្រហម (គំនូសតាងទី ២២)។

ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសន៍ទាំងអស់ សាលាក្ដីខ្មែរក្រហម (៨១ភាគរយ) ត្រូវបានគេស្គាល់ច្រើនជាង អ.វ.ត.ក (៤៧ ភាគរយ) ហើយដូចគ្នាដែរសម្រាប់ក្រុមសំណាកនីមួយៗ ដែលសាលាក្ដីខ្មែរក្រហមត្រូវបានគេស្គាល់ច្រើនជាង។

សម្រាប់ទាំងសាលាក្ដីខ្មែរក្រហម និងអ.វ.ត.ក លទ្ធផលបង្ហាញថាបុរសស្គាល់ច្រើនជាងស្ត្រី ហើយសម្រាប់និស្សិត សាស្ត្រាចារ្យវិញ ក្រុមនេះមានការយល់ដឹងអំពីសាលាក្ដីខ្មែរក្រហម និងអ.វ.ត.ក ច្រើនជាងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាជនទូទៅ។ ស្រដៀងគ្នានេះដែរ អ្នកផ្ដល់បទសម្ភាសន៍ដែលមានកម្រិតការសិក្សាអប់រំខ្ពស់ មានការយល់ដឹងច្រើនជាងអ្នកដែលមានកម្រិតការសិក្សាអប់រំទាប។





**គំនូសតាងទី ២១៖ តើអ្នកធ្លាប់ឮឈ្មោះអ.វ.ត.កដែរឬទេ?**




**គំនូសតាងទី ២២៖ តើអ្នកធ្លាប់ឮឈ្មោះសាលាក្ដីខ្មែរក្រហមដែរឬទេ?**




លទ្ធផលក្នុងគំនូសតាងទី២៣បានបង្ហាញថា អ្នកផ្ដល់បទសម្ភាសន៍ភាគច្រើនបានដឹងអំពីគោលបំណងរបស់អ.វ.ត.ក/សាលាក្ដីខ្មែរក្រហម ដោយ៩៦ភាគរយនៃអ្នកផ្ដល់បទសម្ភាសន៍ជឿជាក់ថា អ.វ.ត.ក ធ្វើការលើករណីទាក់ទងជាមួយរបបខ្មែរក្រហម និងនាំយកអ្នកទទួលខុសត្រូវលើរបបខ្មែរក្រហមទាំងនោះមកឱ្យប្រឈមមុខជាមួយយុត្តិធម៌តាមផ្លូវច្បាប់។ ទោះជាយ៉ាងណាក្ដី មានអ្នកផ្ដល់បទសម្ភាសន៍ចំនួន២៣ភាគរយបានយល់ច្រឡំថា អ.វ.ត.ក/សាលាក្ដីខ្មែរក្រហម មានតួនាទីនៅក្នុងការដោះស្រាយជម្លោះអំពីការរំលោភបំពានសិទ្ធិមនុស្សដែលមិនទាក់ទងនឹងរបបខ្មែរក្រហម ខណៈដែលអ្នកផ្ដល់បទសម្ភាសន៍មួយចំនួនតូចជឿថាវាមានតួនាទីដូចជាដោះស្រាយបញ្ហាជម្លោះអាជីវកម្ម ឬជម្លោះក្នុងគ្រួសារ។ ដូច្នេះ តួនាទីរបស់អ.វ.ត.ក/សាលាក្ដីខ្មែរក្រហមគួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈឱ្យបានកាន់តែច្បាស់ដើម្បីកុំឱ្យមានការភាន់ច្រឡំបែបនេះតទៅទៀត។

**គំនូសតាងទី ២៣៖ តើអ.វ.ត.ក/សាលាក្តីខ្មែរក្រហមមានតួនាទីអ្វីខ្លះ? (ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក)**







ប្រហែលជា៦៨ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍ដែលធ្លាប់ស្គាល់អ.វ.ត.ក/សាលាក្តីខ្មែរក្រហម គិតថាអ.វ.ត.ក គឺជាតុលាការមានសមាសភាគចម្រុះចូលគ្នារវាងភាគីកម្ពុជា និងភាគីអន្តរជាតិ ខណៈដែល១៤ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍ជឿថាអ.វ.ត.ក គឺជាតុលាការជាតិកម្ពុជា និង១១ភាគរយថា គឺជាតុលាការអន្តរជាតិ។ អ្នកផ្តល់បទសម្ភាសន៍ជាបុរសហាក់ដូចជាមានចំណេះដឹងច្រើនជាងស្ត្រីបន្តិចទៅលើបញ្ហានេះ ខណៈដែលអ្នកផ្តល់បទសម្ភាសន៍ជានិស្សិត សាស្ត្រាចារ្យមានចំណេះដឹងច្រើនជាងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាជនទូទៅ ។

**គំនូសតាងទី ២៤៖ ប្រភេទនៃ អ.វ.ត.ក ចាត់ថ្នាក់ទៅតាមភេទ និងតាមសំណាក**




ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ដែលស្គាល់ អ.វ.ត.ក/សាលាក្តីខ្មែរក្រហម មានចំនួន៤៦ភាគរយជឿថាទាំងអន្តរជាតិ និងរដ្ឋាភិបាលកម្ពុជាជាអ្នកផ្តត់ផ្គង់ហិរញ្ញវត្ថុដល់ អ.វ.ត.ក។ ទោះជាយ៉ាងណាមាន២៦ ភាគរយទៀតគិតថាម្ចាស់ជំនួយគឺជាអង្គការសង្គមស៊ីវិល ឬឯកជនជាអ្នកផ្តល់ជំនួយដល់ អ.វ.ត.ក និង២១ភាគរយផ្សេងទៀតគិតថាមានតែម្ចាស់ជំនួយអន្តរជាតិតែប៉ុណ្ណោះដែលជាអ្នកផ្តត់ផ្គង់ហិរញ្ញវត្ថុដល់ អ.វ.ត.ក។ មានអ្នកផ្តល់បទសម្ភាសន៍ត្រឹមតែ៤ភាគរយប៉ុណ្ណោះដែលគិតថា អ.វ.ត.ក ត្រូវបានផ្តត់ផ្គង់ហិរញ្ញវត្ថុដោយរដ្ឋាភិបាលកម្ពុជាតែមួយគត់។

**គំនូសតាងទី ២៥៖ តើអ្នកគិតថានរណាជាម្ចាស់ជំនួយផ្តត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់អ.វ.ត.ក (ចាត់ថ្នាក់ទៅតាមភេទ និងសំណាក)**




## /// ៣.៦ ///
## ការរក្សាទុកប្រវត្តិសាស្ត្រ និងកំណត់ត្រារបស់ អ.វ.ត.ក

គោលបំណងនៅក្នុងផ្នែកនេះគឺដើម្បីវាស់វែងចំណេះដឹងរបស់អ្នកផ្តល់បទសម្ភាសន៍អំពីស្ថាប័ននានា ដែលអាចត្រូវបានយកទៅពិចារណាថាមានសក្តានុពលធ្វើជាបេក្ខជនក្នុងការថែរក្សា និងអភិរក្សប្រវត្តិសាស្ត្រ និងកំណត់ត្រារបស់អ.វ.ត.ក។ លើសពីនេះទៅទៀត វាបានបង្ហាញពីការយល់ឃើញជារួមរបស់អ្នកផ្តល់បទសម្ភាសន៍អំពីលក្ខណៈសម្បត្តិ និងស្ថាប័នជាក់លាក់ដែលគេជឿថា គួរតែទទួលបានការឃុំគ្រងលើ និងការទទួលខុសត្រូវចំពោះការថែរក្សា បណ្ណសាររបស់ អ.វ.ត.ក សម្រាប់មនុស្សជំនាន់ក្រោយនាពេលអនាគត។

លទ្ធផលត្រូវបានបង្ហាញនៅក្នុងគំនូសតាងទី ២៦ (អ្នកផ្តល់បទសម្ភាសន៍សរុប, ចាត់ថ្នាក់តាមភេទ), នៅក្នុងគំនូសតាងទី២៧ (ចាត់ថ្នាក់តាមសំណាក) និងគំនូសតាងទី២៨ (ចាត់ថ្នាក់តាមកម្រិតការសិក្សាអប់រំ)។

សរុបមក លទ្ធផលនៅក្នុងគំនូសតាងទី២៦ បង្ហាញថា គ្មានស្ថាប័នណាមួយត្រូវបានស្គាល់ដោយអ្នកផ្តល់បទសម្ភាសន៍ភាគច្រើននោះទេ។ ស្ថាប័នដែលអ្នកផ្តល់បទសម្ភាសន៍ស្គាល់ច្រើនជាងគេរួមមាន៖ បណ្ណាល័យជាតិ (៣៥ ភាគរយ) បណ្ណាល័យសម្តេចហ៊ុន សែន (៣៤ភាគរយ) និងមជ្ឈមណ្ឌលឯកសារកម្ពុជា (៣០ ភាគរយ)។ ដូចដែលបានបង្ហាញនៅក្នុងគំនូសតាងទី២៧ មានតែនិស្សិត និងសាស្ត្រាចារ្យប៉ុណ្ណោះដែលមានចំណេះដឹងគួរឲ្យកត់សម្គាល់អំពីស្ថាប័នទាំងនោះ (បណ្ណាល័យជាតិមាន៨១ភាគរយ បណ្ណាល័យសម្តេចហ៊ុន សែន មាន៧១ភាគរយ បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមាន៧០ភាគរយ និងមជ្ឈមណ្ឌលឯកសារកម្ពុជាមាន៤៩ភាគរយ)។ សម្រាប់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាជនទូទៅ ស្គាល់ច្រើនជាងគេគឺមជ្ឈមណ្ឌលឯកសារកម្ពុជា (២២ភាគរយ)។

## គំនូសតាងទី ២៦៖ ការចាត់ថ្នាក់ពីការស្គាល់ឈ្មោះស្ថាប័ននានាទៅតាមភេទ




## គំនូសតាងទី ២៧៖ ការស្គាល់ឈ្មោះស្ថាប័ននានា នៅតាមចំណាត់ថ្នាក់របស់សំណាក





Photo by Chy Terith / Documentation Center of Cambodia Archives



## គំនូសតាងទី ២៨៖ ការស្គាល់ឈ្មោះស្ថាប័ននានា នៅតាមកម្រិតការសិក្សាអប់រំ




សម្រាប់ស្ថាប័នដែលពួកគេស្គាល់ យើងបានសុំឲ្យអ្នកផ្តល់បទសម្ភាសន៍ដាក់ពិន្ទុពី១ដល់៥ លើកម្រិតអព្យាក្រឹតភាព/ឯករាជ្យភាព ភាពជឿទុកចិត្តបាន និងភាពច្បាស់លាស់របស់ស្ថាប័ននីមួយៗ។ ត្រង់នេះសំខាន់ណាស់ដែលត្រូវគូសបញ្ជាក់ថា ស្ថាប័នដែលមិនសូវមានគេស្គាល់ ទទួលបានការឆ្លើយតបតិចតួចណាស់ទៅលើសំណួរនេះ។

ជាទូទៅ អ្នកផ្តល់បទសម្ភាសន៍មានទំនោរទៅរកការដាក់ពិន្ទុដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាចំពោះលក្ខណៈសម្បត្តិ និងចំពោះស្ថាប័ននីមួយៗ។ ពិន្ទុជាមធ្យមសម្រាប់លក្ខណៈសម្បត្តិទាំងអស់ និងសម្រាប់ស្ថាប័ននីមួយៗចាប់ពី ៣.៧២ ទៅ៤.២៥។ ដូច្នេះវាមានការពិបាកក្នុងការទាញសេចក្តីសន្និដ្ឋានយកជាបានការណាមួយ ចេញពីសំណួរនេះណាស់។

**តារាងទី ៩៖ កម្រិតនៃការយល់ស្របជាមធ្យមចំពោះលក្ខណៈសម្បត្តិរបស់ស្ថាប័ននីមួយៗ**

| ស្ថាប័ន | លក្ខណៈសម្បត្តិ | ការអង្កេត | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|---|
| .១ បណ្ណាល័យ សម្តេចហ៊ុន សែន | អព្យាក្រឹតភាព និងឯករាជ្យភាព | ៣៨០ | ៣,៨៣ | ០,៩១៩៦៧០ | ១ | ៥ |
| | ជឿទុកចិត្ត | ៣៨៦ | ៣,៩០ | ០,៨៩៦៥៣៥ | ១ | ៥ |
| | ច្បាស់លាស់ | ៣៨២ | ៣,៨៩ | ០,៩២៨៦៩០ | ១ | ៥ |
| .២ មជ្ឈមណ្ឌលឯកសារកម្ពុជា | អព្យាក្រឹតភាព និងឯករាជ្យភាព | ៤៤៧ | ៤,២៤ | ០,៧៧០៦២៦ | ១ | ៥ |
| | ជឿទុកចិត្ត | ៤៤៧ | ៤,២២ | ០,៧៨៨៩៧៨ | ១ | ៥ |
| | ច្បាស់លាស់ | ៤៥១ | ៤,២៥ | ០,៧៤១៨៩១ | ១ | ៥ |
| .៣ មជ្ឈមណ្ឌលឯកសារច្បាប់ | អព្យាក្រឹតភាព និងឯករាជ្យភាព | ១១៩ | ៣,៧៥ | ០,៩៣១៧២៤ | ១ | ៥ |
| | ជឿទុកចិត្ត | ១២០ | ៣,៧៩ | ០,៩៥១៧៤២ | ១ | ៥ |
| | ច្បាស់លាស់ | ១១៩ | ៣,៨៤ | ០,៩៨២៧៦០ | ១ | ៥ |
| .៤ បណ្ណាល័យ ក្រសួងយុត្តិធម៌ | អព្យាក្រឹតភាព និងឯករាជ្យភាព | ១៧៩ | ៣,៩៣ | ០,៩៣៩៧៤៥ | ១ | ៥ |
| | ជឿទុកចិត្ត | ១៨០ | ៣,៩៤ | ០,៩១០៣០០ | ១ | ៥ |
| | ច្បាស់លាស់ | ១៨០ | ៣,៩៤ | ០,៩១៣៧២១ | ១ | ៥ |
| .៥ បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច | អព្យាក្រឹតភាព និងឯករាជ្យភាព | ៣០៩ | ៣,៨៦ | ០,៨៥៦០៩៨ | ១ | ៥ |
| | ជឿទុកចិត្ត | ៣១៥ | ៣,៩០ | ០,៨១៦៩០៥ | ១ | ៥ |
| | ច្បាស់លាស់ | ៣១៣ | ៣,៩០ | ០,៨៨០៥៧៧ | ១ | ៥ |
| .៦ បណ្ណសារដ្ឋានជាតិ | អព្យាក្រឹតភាព និងឯករាជ្យភាព | ៣៧ | ៤,០៣ | ០,៨៩៧១០៩ | ១ | ៥ |
| | ជឿទុកចិត្ត | ៣៧ | ៣,៩២ | ០,០៦៤០១៧ | ១ | ៥ |
| | ច្បាស់លាស់ | ៣៨ | ៤,០៨ | ០,៩១១៨៣២ | ១ | ៥ |
| .៧ បណ្ណាល័យ ជាតិ | អព្យាក្រឹតភាព និងឯករាជ្យភាព | ៤៣១ | ៤,០៣ | ០,៧៥៧១០៣ | ១ | ៥ |
| | ជឿទុកចិត្ត | ៤៣៥ | ៤,០៦ | ០,៨០៤១៨៨ | ១ | ៥ |
| | ច្បាស់លាស់ | ៤៣៤ | ៤,០៥ | ០,៨១៤២៤៧ | ១ | ៥ |
| .៨ រាជបណ្ឌិត្យ សភាកម្ពុជា | អព្យាក្រឹតភាព និងឯករាជ្យភាព | ២២៩ | ៣,៧២ | ១,០៨៨៤៤៣ | ១ | ៥ |
| | ជឿទុកចិត្ត | ២៣០ | ៣,៧៨ | ១,០៥៦៦៧២ | ១ | ៥ |
| | ច្បាស់លាស់ | ២២៨ | ៣,៨៤ | ១,៩៩៨៤៩២ | ១ | ៥ |
| .៩ បណ្ណាល័យ ព្រឹទ្ធសភា | អព្យាក្រឹតភាព និងឯករាជ្យភាព | ១៥៩ | ៣,៩២ | ១,៩៧៤១៥០ | ១ | ៥ |
| | ជឿទុកចិត្ត | ១៥៨ | ៣,៩៤ | ១,៩៥៩៣២៣ | ១ | ៥ |
| | ច្បាស់លាស់ | ១៥៨ | ៣,៩៤ | ១,៩៨៨៣៦៣ | ១ | ៥ |

អ្នកផ្តល់បទសម្ភាសន៍ត្រូវបានសួរសំណួរ (ទាក់ទងទៅនឹងស្ថាប័នដែលគេបានស្គាល់) ថាតើវាល្អដែរឬទេប្រសិនបើបណ្ណសារ និងកំណត់ត្រារបស់អ.វ.ត.កត្រូវបានរក្សានៅក្នុងស្ថាប័នទាំងនោះ។ ជាថ្មីម្តងទៀត អ្នកផ្តល់បទសម្ភាសន៍ត្រូវដាក់ពិន្ទុចំពោះកម្រិតនៃការយល់ស្របរបស់ខ្លួនពី១ទៅ៥។ ស្រដៀងគ្នាទៅនឹងសំណួរពីមុន អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនមានទំនោរដាក់ពិន្ទុ ៣ឬ៤ ចំពោះស្ថាប័ននីមួយៗ។ ស្ថាប័នដែលមានពិន្ទុជាមធ្យមខ្ពស់បំផុតគឺ បណ្ណាល័យជាតិ (៤.១២) និងមជ្ឈមណ្ឌលឯកសារកម្ពុជា (៤.០៩) ខណៈដែលជាទូទៅអ្នកផ្តល់បទសម្ភាសន៍ភាគច្រើនផ្តល់ពិន្ទុទៅលើ “ទីតាំងមានសុវត្ថិភាព និងមានសន្តិសុខល្អ” (៤.៥៨)។

**តារាងទី ១០៖ កម្រិតនៃការយល់ស្របជាមធ្យមចំពោះការរក្សាបណ្ណសាររបស់ អ.វ.ត.ក**

| ទីតាំង | ការអង្កេត | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|
| .១ ... សុវត្ថិភាព និងសន្តិសុខល្អ | ១,៥៣៣ | ៤,៥៨ | ០,៥៤៨៦៣៩ | ១ | ៥ |
| .២.១ ... មជ្ឈមណ្ឌលឯកសារកម្ពុជា | ៤៥៤ | ៤,០៩ | ០,៨៧៧៦៤៤ | ១ | ៥ |
| .២.២ ... បណ្ណាល័យសម្តេចហ៊ុន សែន | ៥០៨ | ៣,៧៥ | ១,១០៦៩៥៣ | ១ | ៥ |
| .២.៣ ... មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ | ១៨៣ | ៤,០៣ | ០,៩៥៧៥១៣ | ១ | ៥ |
| .២.៤ ... បណ្ណាល័យក្រសួងយុត្តិធម៌ | ២៤៧ | ៤,០២ | ០,៩៤៧៦០៩ | ១ | ៥ |
| .២.៥ ... បណ្ណាល័យសាកលវិទ្យាលយ័ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ៤១៩ | ៣,៦៧ | ១,០០៣៨៤៧ | ១ | ៥ |
| .២.៦ ... បណ្ណសារដ្ឋានជាតិ | ៥៩ | ៤,០៥ | ០,៩៧២៤៤៣ | ១ | ៥ |
| .២.៧ ... បណ្ណាល័យជាតិ | ៥៣១ | ៤,១២ | ០,៨៧៩៣១៩ | ១ | ៥ |
| .២.៨ ... រាជបណ្ឌិត្យសភាកម្ពុជា | ២៧៩ | ៣,៧២ | ១,១៥១៥២៥ | ១ | ៥ |
| .២.៩ ... បណ្ណាល័យព្រឹទ្ធសភា | ២១៤ | ៣,៧៥ | ១,០៨៣១០៥ | ១ | ៥ |
| .២.១០ ... សាកលវិទ្យាល័យនានានៅក្នុងស្រុក | ១៣៨២ | ៣,៧៧ | ១,១៩៩២៣៧ | ១ | ៥ |
| .២.១១ ... សាកលវិទ្យាល័យនានានៅក្រៅស្រុក | ១៣៦៤ | ៣,២២ | ១,៣៩៦៦២៩ | ១ | ៥ |
| .២.១២ ... ស្ថាប័នអន្តរជាតិ/អង្គការក្រៅរដ្ឋាភិបាលនៅក្រៅស្រុក | ១៣៧១ | ៣,៥០ | ១,៣១៤៣៦១ | ១ | ៥ |

លទ្ធផលនៅក្នុងគំនូសតាងទី២៩ ចង្អុលបង្ហាញថាអ្នកផ្តល់បទសម្ភាសន៍ស្ទើរតែទាំងអស់ (៩៦ភាគរយ) យល់ស្របថា វាពិតជាមានសារៈសំខាន់ណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវតែរក្សានៅក្នុងកន្លែងដែលមានសុវត្ថិភាព និងមានសន្តិសុខល្អ។

/// ៣ ///
លទ្ធផលការស្រាវជ្រាវ និងការវិភាគ

### គំនូសតាងទី ២៩៖ កម្រិតនៃការយល់ស្របចាត់ថ្នាក់ទៅតាមភេទ សំណាក និងកម្រិតការសិក្សាអប់រំ




អ្នកផ្ដល់បទសម្ភាសន៍ត្រូវបានស្នើសុំឲ្យវាយតម្លៃលើសារៈសំខាន់ (១ដល់៥) នៃលក្ខណៈសម្បត្តិរបស់ស្ថាប័នដែលរក្សាទុកឯកសារ និងកំណត់ត្រារបស់អ.វ.ត.ក។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី១១ អ្នកផ្ដល់បទសម្ភាសន៍បានផ្ដល់ពិន្ទុខ្ពស់ (ពិន្ទុជាមធ្យមពី ៣.៩៥ ដល់ ៤.៤៨) ទៅដល់គ្រប់ចំណុចទាំងអស់ លើកលែងតែចំណុចដែលមានការពាក់ព័ន្ធជាមួយ ឬទទួលឥទ្ធិពលពីទិដ្ឋភាពនយោបាយ (២.៣៣ពិន្ទុ) តែប៉ុណ្ណោះ។

### តារាងទី ១១៖ ពិន្ទុជាមធ្យមលើលក្ខណៈសម្បត្តិរបស់ស្ថាប័នដែលរក្សាទុកបណ្ណសាររបស់អ.វ.ត.ក

| លក្ខណៈសម្បត្តិ | ការអង្កេត | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|
| .១... ជាកន្លែងដែលគួរឲ្យទុកចិត្ត និងជឿជាក់បានពីសំណាក់ប្រជាជនកម្ពុជា | ១៥៣៨ | ៤.៤៨ | ០.៥៧៨១៧២ | ១ | ៥ |
| .២ ... ជាស្ថាប័នរបស់កម្ពុជា | ១៥២៤ | ៤.០០ | ០.៩៧៥៤០១ | ១ | ៥ |
| .៣ ... ជាកន្លែងឯករាជ្យ និងអព្យាក្រឹត | ១៥៣៤ | ៤.៤២ | ០.៦៣៣៨៧៥ | ១ | ៥ |
| .៤ ... ជាកន្លែងដែលមានទំនាក់ទំនងអន្តរជាតិ | ១៥០៧ | ៤.០៥ | ០.៩០៤១២៤ | ១ | ៥ |
| .៥ ... ជាកន្លែងដែលមានភាពឯករាជ្យ និងមាននិរន្តរភាពខាងហិរញ្ញវត្ថុ | ១៥០២ | ៣.៩៥ | ០.៩២៣៥០៨ | ១ | ៥ |
| .៦ ... ជាកន្លែងមានប្រព័ន្ធរក្សាឯកសារដោយ cloud/IT និងជាមជ្ឈមណ្ឌលរក្សាទិន្នន័យដែលមានសុវត្ថិភាព | ១៥០១ | ៤.២៣ | ០.៨៦៥៨៧៩ | ១ | ៥ |
| .៧ ... ជាស្ថាប័នអន្តរជាតិ ឬជាសកល | ១៥២០ | ៤.០៣ | ០.៩៧៨៥៧៥ | ១ | ៥ |
| .៨ ... ជាកន្លែងដែលពាក់ព័ន្ធនឹងនយោបាយឬទទួលឥទ្ធិពលពីនយោបាយ | ១៤៤៩ | ២.៣៣ | ១.២៥៤៣៦៦ | ១ | ៥ |
| .៩ ... ផ្ដល់ភាពងាយស្រួលដល់ប្រជាជនកម្ពុជា | ១៥៣៥ | ៤.៣៩ | ០.៧២៥៧១៨ | ១ | ៥ |
| .១០... មានបទពិសោធន៍ជាមួយសាលាក្ដីខ្មែរក្រហម | ១៤៨៥ | ៣.៩៩ | ០.៩៣១២៤៣ | ១ | ៥ |





### គំនូសតាងទី ៣០៖ លក្ខណៈសម្បត្តិនៃស្ថាប័នដែលសក្តិសមនឹងរក្សាបណ្ណសាររបស់អ.វ.ត.ក ចាត់ថ្នាក់ទៅតាមភេទ



**គំនូសតាងទី ៣១ ៖ លក្ខណៈសម្បត្តិនៃស្ថាប័នដែលសក្តិសមនឹងរក្សាបណ្ណសាររបស់អ.វ.ត.ក ចាត់ថ្នាក់ទៅតាមសំណាក**




ដើម្បីផ្តល់ការយល់ដឹងឲ្យបានស៊ីជម្រៅទៅលើបញ្ហាស្មុគស្មាញមួយនេះ យើងបានធ្វើការសាកសួរទៅកាន់អ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន១៧រូប ថាតើលក្ខណៈសម្បត្តិណាខ្លះដែលមានសារៈសំខាន់។ ដូចដែលបានបង្ហាញនៅក្នុងគំនូសតាងទី៣២ អ្នកផ្តល់ព័ត៌មានសំខាន់ៗ បានចង្អុលបង្ហាញពីតម្រូវការរបស់ស្ថាប័នទាំងនោះគួរតែមានប្រព័ន្ធរក្សាទិន្នន័យសុវត្ថិភាពអនឡាញ ឬខ្លោត (online/cloud) និងដើម្បីផ្តល់ភាពងាយស្រួលសម្រាប់ប្រជាជនកម្ពុជាអាចស្វែងរកបាន។ លក្ខណៈវិនិច្ឆ័យផ្សេងទៀតមានដូចជា ត្រូវមានគោលនយោបាយត្រឹមត្រូវក្នុងការរក្សាបណ្ណសារ សមត្ថភាពបច្ចេកទេសនៃធនធានមនុស្ស អគារ និងឧបករណ៍ទំនើបៗ និងសមត្ថភាពនៃស្ថាប័ន ដែលអាចបំប្លែងបណ្ណសារទាំងនោះឲ្យក្លាយជាទម្រង់ឌីជីថល (Digitalized) បាន។

**គំនូសតាងទី ៣២៖ លក្ខណៈសម្បត្តិនៃស្ថាប័នដែលសមនឹងរក្សាបណ្ណសារ (សម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ)**




អ្នកផ្តល់បទសម្ភាសន៍ត្រូវបានសួរថាតើកន្លែងណាដែលខ្លួនចង់ឲ្យរក្សាទុកបណ្ណសាររបស់អ.វ.ត.ក។ ចម្លើយរបស់ផ្តល់បទសម្ភាសន៍ត្រូវបានបង្ហាញនៅគំនូសតាងទី៣៣ (សម្រាប់អ្នកផ្តល់បទសម្ភាសន៍ទាំងអស់ និងចាត់ថ្នាក់តាមភេទ) និងនៅគំនូសតាងទី៣៤ (ចាត់ថ្នាក់តាមសំណាក)។ ចំណុចសំខាន់ដែលគួរឲ្យកត់សម្គាល់គឺ អ្នកផ្តល់បទសម្ភាសន៍បានផ្តល់នូវចម្លើយធំទូលាយពេក រហូតដល់មិនមានស្ថាប័នណាមួយដែលទទួលបានចម្លើយលើសពី១៦ភាគរយនោះទេ។ ទោះបីជាវាអាចឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកផ្តល់បទសម្ភាសន៍ថាមានស្ថាប័នជាច្រើនដែលមានសមត្ថភាពរក្សាទុកបណ្ណសារទាំងនោះក្តី វាក៏ប្រហែលជាទំនងដែរថា ចម្លើយរបស់អ្នកផ្តល់បទសម្ភាសន៍ ឆ្លុះបញ្ចាំងឱ្យឃើញថា អ្នកទាំងនោះគ្មានព័ត៌មានលម្អិតគ្រប់គ្រាន់អំពីស្ថាប័នដែលមានសមត្ថភាពក្នុងការរក្សាបណ្ណសារទាំងនោះ ទេ។

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ ស្ថាប័នដែលត្រូវបានលើកឡើងច្រើនជាងគេរួមមាន៖ បណ្ណាល័យជាតិ (១៦ភាគរយ) មជ្ឈមណ្ឌលឯកសារកម្ពុជា (១៣ភាគរយ) បណ្ណាល័យសម្តេចហ៊ុន សែន (១២ភាគរយ) និងបណ្ណាល័យ ក្រសួងយុត្តិធម៌ (១២ភាគរយ)។ ទោះជាមានភាគរយខុសគ្នាមួយចំនួនរវាងសំណាកនីមួយៗក្តី ស្ថាប័នទាំងបួននេះជាស្ថាប័នដែលត្រូវបានជ្រើសរើសច្រើនជាងគេ សម្រាប់ក្រុមសំណាកនីមួយៗ។

## គំនូសតាងទី ៣៣៖ ស្ថាប័នដែលអ្នកចង់ឲ្យរក្សាទុកបណ្ណសាររបស់អ.វ.ត.ក (ចាត់ថ្នាក់តាមភេទ)




## គំនូសតាងទី ៣៤៖ ស្ថាប័នដែលអ្នកចង់ឲ្យរក្សាទុកបណ្ណសាររបស់អ.វ.ត.ក (ចាត់ថ្នាក់តាមសំណាក)



ដោយសារប្រជាជនទូទៅមានការពិបាកក្នុងការដឹងថា ស្ថាប័នណាគួរតែជាអ្នករក្សាទុកបណ្ណសារ សំណួរដូចគ្នានេះដែរត្រូវបានសួរទៅកាន់អ្នកផ្ដល់ព័ត៌មានសំខាន់ៗ ទាំង១៧នាក់។ ដូចដែលបានបង្ហាញនៅក្នុងគំនូសតាងទី៣៥ ស្ថាប័នដែលជាអ្នកផ្ដល់ព័ត៌មានសំខាន់ៗបានលើកឡើងច្រើនជាងគេគឺមជ្ឈមណ្ឌលឯកសារកម្ពុជា។  អ្នកផ្ដល់ព័ត៌មានសំខាន់ៗ មួយចំនួនតូច បានជឿថាបណ្ណសារគួរតែត្រូវបានរក្សាទុកនៅក្នុងបណ្ណាល័យជាតិ ឬបណ្ណាល័យនៃក្រសួងយុត្តិធម៌ ដែលផ្ទុយពីលទ្ធផលនៃការស្ទង់មតិទាំងមូល។

លើសពីនេះទៅទៀត អ្នកផ្ដល់ព័ត៌មានសំខាន់ៗលើកឡើងថា បណ្ណសាររបស់អ.វ.ត.កត្រូវតែរក្សាទុកនៅក្នុងប្រទេសកម្ពុជាពីព្រោះតែវាជាបណ្ណសាររបស់ប្រទេសកម្ពុជា។ ទាក់ទងចំណុចនេះ ក៏មានការលើកឡើងដែរថា ភាពជាដៃគូរវាងស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលពិតជាមានសារៈសំខាន់ណាស់។ ស្ថាប័នរដ្ឋាភិបាលគួរតែទទួលខុសត្រូវទៅលើការរក្សាទុក និងរក្សាសុវត្ថិភាពនៃបណ្ណសាររបស់ អ.វ.ត.ក ហើយអង្គការសង្គមស៊ីវិលគួរតែជួយលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបណ្ណសារទាំងនោះ។អ្នកផ្ដល់ព័ត៌មានសំខាន់ៗមួយចំនួនបានលើកឡើងថាបណ្ណសារទាំងនោះគួរតែរក្សាទុកនៅក្នុងស្ថាប័នមានជំនាញផ្នែកច្បាប់ និង/ឬ មានជំនាញរក្សាទុកឯកសារនៃការចងចាំនិងជាប្រវត្តិសាស្ត្រជាដើម។ លើសពីនេះទៀតក៏មានការលើកឡើងដែរថា គណៈកម្មាធិការមួយដើម្បីគ្រប់គ្រង និងរក្សាបណ្ណសារ គួរតែត្រូវបង្កើតឡើងដោយមានអភិបាលកិច្ចដ៏រឹងមាំ និងមានតម្លាភាព និងចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការល្អរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។

**គំនូសតាងទី ៣៥៖ តើបណ្ណសារនៃអ.វ.ត.កគួរតែត្រូវបានរក្សាទុកនៅឯណា? (សម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់ៗ)**






Photo by Chy Terith / Documentation Center of Cambodia Archives

## /// ៣.៧ ///
## ចំណេះដឹងអំពី កម្មវិធី ព្រឹត្តិការណ៍ និងសកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

គោលបំណងនៅក្នុងផ្នែកនេះ គឺដើម្បីធ្វើការវាយតម្លៃចំណេះដឹងរបស់អ្នកផ្តល់បទសម្ភាសន៍អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (ចំណាំ៖ ភាគច្រើននៃសំណួរទាំងនេះសួរបានត្រឹមតែអ្នកផ្តល់បទសម្ភាសន៍ចំនួន៤៧៦នាក់តែប៉ុណ្ណោះដែលបានបង្ហាញថា អ្នកទាំងនោះស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជា)។ ដូចបានគូសបញ្ជាក់នៅក្នុងគំនូសតាងទី៣៦ អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនដែលស្គាល់ខ្លះៗអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលធ្លាប់បានចូលរួមក្នុងសកម្មភាព ឬព្រឹត្តិការណ៍ណាមួយដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ លទ្ធផលនេះអាចបញ្ជាក់ថា នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងរៀបចំព្រឹត្តិការណ៍ណាមួយសម្រាប់សាធារណៈជនទូទៅ មជ្ឈមណ្ឌលត្រូវតែរិះរកវិធីផ្សព្វផ្សាយអំពីព្រឹត្តិការណ៍ទាំងនោះឲ្យបានល្អទូលំទូលាយ។

**គំនូសតាងទី ៣៦៖ ការចូលរួមក្នុងសកម្មភាព/ព្រឹត្តិការណ៍រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ និងសំណាក)**




មានអ្នកផ្តល់បទសម្ភាសន៍ចំនួន ២៦នាក់ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជាការអញ្ជើញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យចូលរួមក្នុងការជំនុំជម្រះក្តីរបស់អ.វ.ត.ក វគ្គបណ្តុះបណ្តាល វេទិកាបង្រៀនតាមសាលារៀន វេទិកាសាធារណៈ និងវេទិការពិភាក្សាតាមភូមិ និងការសម្តែងល្ខោននិយាយ "ទម្លាយភាពស្ងៀមស្ងាត់" ជាដើម។





**គំនូសតាងទី ៣៧៖ ប្រសិនបើអ្នកធ្លាប់បានចូលរួមព្រឹត្តិការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា តើអ្នកធ្លាប់ចូលរួមព្រឹត្តិការណ៍ណាមួយ (ចាត់ថ្នាក់តាមភេទ និងសំណាក)?**




អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនដែលបានចូលរួមព្រឹត្តិការណ៍ទាំងនោះគឺជានិស្សិត និងសាស្ត្រាចារ្យ (២០នាក់ក្នុងចំណោម២៦នាក់)។ ដូចបានគូសបញ្ជាក់នៅក្នុងគំនូសតាងទី៣៨ អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនបានយល់ស្របថាព្រឹត្តិការណ៍ដែលពួកគេបានចូលរួមមានសារៈសំខាន់ និងគួរឲ្យចាប់អារម្មណ៍។ នៅពេលបកស្រាយរូបភាពខាងក្រោមសូមចងចាំថាចំនួនអ្នកផ្តល់បទសម្ភាសន៍ (N) មានចំនួនតូចណាស់សម្រាប់ក្រុមសំណាកមួយចំនួន។

**គំនូសតាងទី ៣៨៖ កម្រិតនៃការយល់ស្របទៅលើប្រយោគដែលទាក់ទងនឹងព្រឹត្តិការណ៍ដែលអ្នកបានចូលរួម (ចាត់ថ្នាក់តាមភេទ និងតាមសំណាក)**



ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន ៤៧៦នាក់ ដែលស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជា មានតែ ១១នាក់ (៩នាក់ជានិស្សិតសាស្ត្រាចារ្យ និង២នាក់ទៀតជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម) តែប៉ុណ្ណោះដែលធ្លាប់ទៅការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកដែលធ្លាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺក្នុងគោលបំណងសិក្សាស្រាវជ្រាវ ឬផ្នែកមួយនៃ "ទស្សនកិច្ចសិក្សា" ដោយផ្ទាល់។

**គំនូសតាងទី ៣៩៖ តើអ្នកធ្លាប់ទៅការិយាល័យកណ្តាលនៅភ្នំពេញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? (ចាត់ថ្នាក់តាមភេទ និងតាមសំណាក)**




**គំនូសតាងទី ៤០៖ ប្រសិនបើអ្នកធ្លាប់ទៅការិយាល័យកណ្តាលនៅភ្នំពេញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, តើអ្នកទៅក្នុងគោលបំណងអ្វី? (ចាត់ថ្នាក់តាមភេទ និងតាមសំណាក)**




អ្នកដែលស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានសុំឲ្យឆ្លើយនូវប្រយោគសំណួរអំពីសកម្មភាព និងលក្ខណៈសម្បត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយដាក់ពិន្ទុពី១ដល់៥។ លទ្ធផលបានបង្ហាញនៅក្នុងតារាងទី១២។ អ្នកផ្តល់បទសម្ភាសន៍ ជាទូទៅ បានឲ្យពិន្ទុពី៤ទៅ៥សម្រាប់ប្រយោគនីមួយៗ ដែលអាចឆ្លុះបញ្ចាំងពីភាពវិជ្ជមានក្នុងការធ្វើការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដូចជាជួយរក្សាប្រវត្តិសាស្ត្រប្រទេសកម្ពុជា (ពិន្ទុជាមធ្យម ៤.៣៩) និងជួយរក្សាការពិតអំពីរបបខ្មែរក្រហម (ពិន្ទុ៤.៣០)។ ជាការកត់សំគាល់ អ្នកផ្តល់បទសម្ភាសន៍មិនយល់ស្របថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលឥទ្ធិពលពីនយោបាយ ឬគណបក្សនយោបាយណាមួយនោះទេ (ពិន្ទុ២.៣៩)។ ព័ត៌មានបន្ថែមចំពោះសំណួរនេះត្រូវបានបង្ហាញនៅគំនូសតាងទី៤១ និងគំនូសតាងទី៤២។





**តារាងទី ១២៖ ពិន្ទុជាមធ្យមនៃកម្រិតយល់ស្របទៅលើមជ្ឈមណ្ឌលឯកសារកម្ពុជា**

Q43. តើអ្នកយល់ស្រប ឬមិនយល់ស្របខ្លាំងកម្រិតណាចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា...

| ប្រយោគ | ការអង្កេត | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|
| .១ ... ជួយចងក្រងឯកសារ និងតាមដានការវិវឌ្ឍ និងលទ្ធផលរបស់សាលាក្តីខ្មែរក្រហម | ៤៤០ | ៤.១៣ | ០.៧៨៤៧៥៦ | ១ | ៥ |
| .២ ... ជួយរក្សាទុកប្រវត្តិសាស្ត្រកម្ពុជាសម្រាប់អ្នកជំនាន់ក្រោយ | ៤៤៩ | ៤.៣៩ | ០.៦៣៩៥១៩ | ១ | ៥ |
| .៣ ... ជួយរក្សាការពិតអំពីរបបខ្មែរក្រហម | ៤៤៩ | ៤.៣០ | ០.៧៧៦៩១៣ | ១ | ៥ |
| .៤ ... ជាស្ថាប័នអព្យាក្រឹត និងឯករាជ្យ | ៤៤៧ | ៤.២៤ | ០.៧៧០៦២៦ | ១ | ៥ |
| .៥ ... ជាស្ថាប័នដែលអាចជឿទុកចិត្តបាន និងមានកេរ្តិ៍ឈ្មោះ | ៤៤៧ | ៤.២២ | ០.៧៨៨៩៧៨ | ១ | ៥ |
| .៦ ... ទទួលរងឥទ្ធិពលនយោបាយ ឬបក្សនយោបាយណាមួយ | ៤០៣ | ២.៣៩ | ១.១៨៤៣០៥ | ១ | ៥ |
| .៧ ... គឺជាប្រភពព័ត៌មានជាក់លាក់ និងច្បាស់លាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម | ៤៥១ | ៤.២៥ | ០.៧៤១៨៩១ | ១ | ៥ |
| .៨ ... គឺជាស្ថាប័នជាក់លាក់ និងច្បាស់លាស់ក្នុងការចងក្រងឯកសារ និងរក្សាប្រវត្តិសាស្ត្រនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម | ៤៤២ | ៤.១៩ | ០.៧៦៦៩៦៨ | ១ | ៥ |



Photo by Keo Dacil / Documentation Center of Cambodia Archives

## គំនូសតាងទី ៤១៖ កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ថ្នាក់ទៅតាមភេទ




## គំនូសតាងទី ៤២៖ កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ថ្នាក់ទៅតាមសំណាក



មានអ្នកផ្តល់បទសម្ភាសន៍តិចតួចប៉ុណ្ណោះដែលនិយាយថាខ្លួនស្គាល់ស្ថាប័នផ្សេងទៀតដែលធ្វើការមានគោលដៅស្រដៀងគ្នាទៅនឹងគោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**គំនូសតាងទី៤៣៖ ការស្គាល់ស្ថាប័នផ្សេងទៀតដែលធ្វើការមានគោលដៅស្រដៀងគ្នាទៅនឹងគោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅតាមភេទ និងតាមសំណាក**






/// ៣ ///
លទ្ធផលការស្រាវជ្រាវ និងការវិភាគ



Photo by Chy Terith / Documentation Center of Cambodia Archives



Photo by Keo Dacil / Documentation Center of Cambodia Archives

# /// ៤ ///
# សេចក្តីសន្និដ្ឋាន

**ការសិក្សានេះបានពិនិត្យទៅលើទស្សនៈរបស់សាធារណៈជនលើតម្រូវការក្នុងការការពារ និងថែរក្សាបណ្ណសាររបស់អ.វ.ត.ក ដោយស្ថាប័នណាមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីថែរក្សាទុកបណ្ណសារទាំងនោះឱ្យបានគត់មត់មិនឱ្យមានការកែប្រែការផ្លាស់ប្តូរ ឬការបំផ្លាញចោលជាដើម។ ការរកឃើញបានបង្ហាញថា អ្នកផ្តល់បទសម្ភាសន៍ច្រើនលើសលប់ (៩៦ភាគរយ) គិតថាវាពិតជាមានសារៈសំខាន់ណាស់ដែលត្រូវរក្សាទុកបណ្ណសារ និងកំណត់ត្រាការកាត់ក្តីរបស់ អ.វ.ត.ក នៅកន្លែងណាដែលមានសុវត្ថិភាព និងមានសន្តិសុខល្អ។ ទស្សនៈដ៏មុតមាំនេះបានលើកឡើងមកដោយអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ ទាំងបុរស ស្ត្រី ប្រជាជនទូទៅ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទាំងនិស្សិត សាស្ត្រាចារ្យ។**

ការសិក្សានេះបានពិនិត្យទៅលើទស្សនៈរបស់សាធារណៈជនលើតម្រូវការក្នុងការការពារ និងថែរក្សាបណ្ណសាររបស់ អ.វ.ត.ក ដោយស្ថាប័នណាមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីថែរក្សាទុកបណ្ណសារទាំងនោះ ឱ្យបានគត់មត់មិនឱ្យមានការកែប្រែ ការផ្លាស់ប្តូរ ឬការបំផ្លាញចោលជាដើម។ ការរកឃើញបានបង្ហាញថា អ្នកផ្តល់បទសម្ភាសន៍ច្រើនលើសលប់ (៩៦ភាគរយ) គិតថាវាពិតជាមានសារៈសំខាន់ណាស់ដែលត្រូវរក្សាទុកបណ្ណសារ និងកំណត់ត្រាការកាត់ក្តីរបស់ អ.វ.ត.ក នៅកន្លែងណាដែលមានសុវត្ថិភាព និងមានសន្តិសុខល្អ។ ទស្សនៈដ៏មុតមាំនេះបានលើកឡើងមកដោយអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ ទាំងបុរស ស្ត្រី ប្រជាជនទូទៅ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទាំងនិស្សិត សាស្ត្រាចារ្យ។

អ្នកផ្តល់បទសម្ភាសន៍ក៏ជឿជាក់ថាបណ្ណសាររបស់ អ.វ.ត.ក ត្រូវតែរក្សាទុកនៅក្នុងស្ថាប័នមួយដែលមានកេរ្តិ៍ឈ្មោះ និងអាចជឿទុកចិត្តបានពីសំណាក់ប្រជាជនកម្ពុជា ជាកន្លែងឯករាជ្យ និងអព្យាក្រឹត ព្រមទាំងជាកន្លែងដែលផ្តល់ភាពងាយស្រួលសម្រាប់ប្រជាជនកម្ពុជាអាចស្វែងរកបាន ថែមទៀតផង។ លើសពីនេះទៅទៀត វាពិតជាមានសារៈសំខាន់ណាស់ដែលស្ថាប័ននោះមានបច្ចេកវិទ្យាចាំបាច់ក្នុងការផ្ទុកទិន្នន័យ (ទីតាំងផ្ទុកទិន្នន័យក្នុងបច្ចេកវិទ្យាខ្លោត កម្មវិធីផ្ទុកទិន្នន័យលើអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព និងមណ្ឌលផ្ទុកទិន្នន័យសុវត្ថិភាព) ក៏ដូចជា សមត្ថភាពបច្ចេកទេសនៃធនធានមនុស្ស រួមទាំងសមត្ថភាពក្នុងការបំប្លែងបណ្ណសារទៅជាទម្រង់ឌីជីថល (Digitalized)។ អ្នកផ្តល់បទសម្ភាសន៍មានទស្សនៈយ៉ាងមុតមាំថា ស្ថាប័នដែលរក្សាទុកបណ្ណសារត្រូវតែជាស្ថាប័នដែលមិនទទួលរងឥទ្ធិពល ឬជាប់ពាក់ព័ន្ធខាងផ្នែកនយោបាយដាច់ខាត។ លើសពីនេះទៅទៀត វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលស្ថាប័នដែលត្រូវជ្រើសរើសត្រូវមានទាំងឆន្ទៈ និងមានការត្រៀមខ្លួនរួចជាស្រេចក្នុងការរក្សាការពារបណ្ណសាររបស់អ.វ.ត.ក។ ទាំងអ្នកផ្តល់បទសម្ភាសន៍ និង អ្នកផ្តល់ព័ត៌មានសំខាន់ៗ ទាំងអស់ដែលបានសម្ភាស បានផ្តល់យោបល់ធំទូលាយអំពីការជ្រើសរើសស្ថាប័នដែលត្រូវរក្សាទុកបណ្ណសាររបស់អ.វ.ត.កទាំង

នោះ។ ភាពខុសគ្នានៃគំនិតយោបល់ទាំងនេះអាចឆ្លុះបញ្ចាំងពីចំណុចមួយចំនួន។ ជាឧទាហរណ៍ វាអាចឆ្លុះបញ្ចាំងថាមានស្ថាប័នជាច្រើនដែលអាចអនុវត្តន៍តួនាទីនេះយ៉ាងមានប្រសិទ្ធភាព ឬអាចឆ្លុះបញ្ចាំងដូចគ្នាថា គ្មានស្ថាប័នជាក់លាក់ណាមួយសម្រាប់តួនាទីមួយនេះទេ។ ម្យ៉ាងទៀត វាក៏អាចឆ្លុះបញ្ចាំងថា អ្នកផ្តល់បទសម្ភាសន៍គ្មានព័ត៌មានគ្រប់គ្រាន់សម្រាប់បញ្ចេញយោបល់អំពីភាពសក្តិសមរបស់ស្ថាប័ននីមួយៗ ក៏ព្រោះតែអ្នកទាំងនោះខ្វះនូវចំណេះដឹង/ព័ត៌មានលម្អិតអំពីសមត្ថភាព និងការងាររបស់ស្ថាប័នទាំងនោះទាក់ទងនឹងការរក្សាទុក និងថែរក្សាបណ្ណសារជាប្រវត្តិសាស្ត្រច្បាប់ដើមដ៏មានសារៈសំខាន់ផ្សេងៗ ទាក់ទងទៅនឹងរបបខ្មែរក្រហម។

ដោយពិចារណាលើលក្ខណៈសម្បត្តិទាំងអស់នេះ ស្ថាប័នចំនួន៤ ដែលអ្នកផ្តល់បទសម្ភាសន៍បានចាត់ទុកថាមានភាពសក្តិសមទទួលរក្សាទុកនូវបណ្ណសាររបស់អ.វ.ត.កគឺ៖ បណ្ណាល័យជាតិ, មជ្ឈមណ្ឌលឯកសារកម្ពុជា, បណ្ណាល័យសម្តេច ហ៊ុន សែន និងបណ្ណាល័យក្រសួងយុត្តិធម៌។ ស្ថាប័នកំពូលគេដែលអ្នកផ្តល់ព័ត៌មានសំខាន់ៗ បានលើកឡើងថាសមជាអ្នកទទួលយកបណ្ណសារនេះទៅថែរក្សា គឺ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណាល័យសម្តេចហ៊ុន សែន បណ្ណសារដ្ឋានជាតិ និងមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់។

លើសពីនេះទៅទៀត អ្នកផ្តល់ព័ត៌មានសំខាន់ៗបានលើកឡើងថាបណ្ណសាររបស់ អ.វ.ត.ក ត្រូវតែរក្សាទុកនៅក្នុងប្រទេសកម្ពុជា ពីព្រោះវាជាបណ្ណសាររបស់ប្រទេសកម្ពុជា។ នៅក្នុងន័យនេះ អ្នកផ្តល់ព័ត៌មានសំខាន់ៗបានលើកឡើងថាភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ពិតជាមានសារៈសំខាន់ណាស់។ អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនបានលើកឡើងថាបណ្ណសារគួរតែត្រូវបានរក្សាទុកដោយស្ថាប័នដែលមានឯកទេសខាងច្បាប់ និង/ឬខាងរក្សាទុកឯកសារនៃការចងចាំ និងឯកសារជាប្រវត្តិសាស្ត្រ។

អ្នកផ្តល់ព័ត៌មានសំខាន់ៗក៏បានលើកឡើងដែរថា គណៈកម្មាធិការកម្រិតខ្ពស់ និងឯករាជ្យមួយ គួរត្រូវបានតែងតាំងឡើងដើម្បីគ្រប់គ្រង និងរក្សាការពារបណ្ណសារ តាមរយៈ អភិបាលកិច្ចរឹងមាំ និងមានតម្លាភាព។



# ឧបសម្ព័ន្ធ

តារាងទី ១៣៖ ការចាត់ថ្នាក់សំណាកប្រជាជនទូទៅ/សាធារណៈ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមខេត្ត

| កូដ | ខេត្ត | ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ការចាត់ថ្នាក់តំបន់ | ប្រជាជនទូទៅ | | អ្នករស់រានមានជីវិត | | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| ១ | ភ្នំពេញ | ពោធិ៍សែនជ័យ | ចោមចៅ | ជម្ពូវ័ន្ត | ប្រជុំជន | ៥ | ៦ | ៤ | ៦ | ២១ |
| | | | | ព្រៃទា | ប្រជុំជន | ២ | ៤ | ២ | ៤ | ១២ |
| | | | | ចោមចៅ | ប្រជុំជន | ២ | ៤ | ២ | ៤ | ១២ |
| | | | | ថ្មគោល | ប្រជុំជន | ២ | ៣ | ២ | ៣ | ១០ |
| | | | | ព្រៃជីសាក់ | ប្រជុំជន | ២ | ៣ | ២ | ៣ | ១០ |
| | ភ្នំពេញ | មានជ័យ | ស្ទឹងមានជ័យ | ឫស្សី | ប្រជុំជន | ៣ | ៤ | ៣ | ៤ | ១៤ |
| | | | | ព្រែកទាល់ | ប្រជុំជន | ២ | ៣ | ២ | ៣ | ១០ |
| | | | | មានជ័យ | ប្រជុំជន | ១ | ២ | ២ | ២ | ៧ |
| | | | | ដំណាក់ធំ | ប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | ដំណាក់ធំ១ | ប្រជុំជន | ១ | ២ | ១ | ២ | ៦ |
| | ភ្នំពេញ | ឫស្សីកែវ | ទួលសង្កែ | ផ្សារតូច | ប្រជុំជន | ១ | ២ | ១ | ២ | ៦ |
| | | | | ទួលសង្កែ | ប្រជុំជន | ៤ | ៦ | ៤ | ៦ | ២០ |
| | | | | ទួលគោក | ប្រជុំជន | ៣ | ៤ | ៣ | ៤ | ១៤ |
| | ភ្នំពេញ | សែនសុខ | ទឹកថ្លា | ត្រពាំងឈូក | ប្រជុំជន | ៤ | ៥ | ៤ | ៥ | ១៨ |
| | | | | ស្លែងរលើង | ប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | ផ្សារទឹកថ្លា | ប្រជុំជន | ១ | ២ | ១ | ២ | ៦ |
| | | | | ចុងថ្នល់ខាងលិច | ប្រជុំជន | ១ | ១ | ១ | ១ | ៤ |
| | | | | ទឹកថ្លា | ប្រជុំជន | ១ | ១ | ១ | ១ | ៤ |
| | ភ្នំពេញ | មានជ័យ | បឹងទំពុន | សន្សំកុសល៣ | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | សន្សំកុសល២ | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | ត្នោតជ្រុំ២ | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | ត្នោតជ្រុំ | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | សន្សំកុសល៤ | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| 2 | បាត់ដំបង | មោងឫស្សី | ជ្រៃ | ដូនទ្រី | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | អង្គ្រង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ចុងចំណាយ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ជ្រៃ២ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ជ្រៃជើង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | បាត់ដំបង | បវេល | បវេល | ព្រៃទទឹងពីរ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | បវេលមួយ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | បវេលពីរ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ

| កូដ | ខេត្ត | ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ការចាត់ថ្នាក់តំបន់ | ប្រជាជនទូទៅ | | អ្នករស់រានមានជីវិត | | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| | | | | សាំងរាំង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | កំពង់ព្នៅ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | បាត់ដំបង | បាណន់ | តាក្រាម | តាង៉ែន | ទីជនបទ | ២ | ៣ | ២ | ៣ | ១០ |
| | | | | អូរពងមាន់ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ថ្មី | ទីជនបទ | ១ | ២ | ១ | ២ | ៦ |
| | | | | ស្លាបប៉ាង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | អន្លង់ស្វាយ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | បាត់ដំបង | បាត់ដំបង | ស្វាយប៉ោ | ព្រែកមហាទេព | ទីប្រជុំជន | ២ | ៣ | ២ | ៣ | ១០ |
| | | | | កំពង់ក្របី | ទីប្រជុំជន | ២ | ១ | ២ | ១ | ៦ |
| | | | | ម្តៃឧសភា | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | កម្មករ | ទីប្រជុំជន | ៤ | ៤ | ៤ | ៤ | ១៦ |
| | បាត់ដំបង | បាណន់ | ស្នឹង | សំបួរមាស | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | ព្រះស្រែ | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | ស្នឹងកើត | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | បឹងប្រី | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| | | | | បឹងក្រសាល | ទីប្រជុំជន | ២ | ២ | ២ | ២ | ៨ |
| ៣ | ព្រៃវែង | ពារាំង | ព្រៃព្នៅ | ព្រៃព្នៅ | ទីជនបទ | ៤ | ៥ | ៤ | ៤ | ១៧ |
| | | | | ព្រៃស្លា | ទីជនបទ | ២ | ៣ | ៣ | ៣ | ១១ |
| | | | | ព្រហ្ម | ទីជនបទ | ១ | ១ | ១ | ១ | ៤ |
| | | | | ស្រម៉ | ទីជនបទ | ១ | ១ | ១ | ១ | ៤ |
| | | | | សាមគ្គី | ទីជនបទ | ១ | ១ | ១ | ១ | ៤ |
| | ព្រៃវែង | កំពង់លាវ | ពោធិ៍រៀង | ពោធិ៍រៀងជើង | ទីជនបទ | ៣ | ៣ | ៣ | ៣ | ១២ |
| | | | | ពោធិ៍រៀងត្បូង | ទីជនបទ | ៤ | ៤ | ៣ | ៣ | ១៤ |
| | | | | វាលព្រៅ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | យាយសល់ | ទីជនបទ | ២ | ២ | ១ | ១ | ៦ |
| | ព្រៃវែង | មេសាង | ជីផុច | ជីផុច | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ថ្មី | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | រាំង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ពោធិ៍រោង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ត្រពាំងស្គន់ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | ព្រៃវែង | មេសាង | ត្រពាំងស្រែ | ស្រម៉ | ទីជនបទ | ២ | ៣ | ២ | ៣ | ១០ |
| | | | | ត្រពាំងស្រែ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |

| កូដ | ខេត្ត | ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ការចាត់ថ្នាក់តំបន់ | ប្រជាជនទូទៅ | | អ្នករស់រានមានជីវិត | | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| | | | | ព្រៃគុយ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ប្រហ៊ួត | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ត្បែង | ទីជនបទ | ១ | ២ | ១ | ២ | ៦ |
| | ព្រៃវែង | កំពង់ត្របែក | គោខ្ចក | ក្រោល | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ស្លា | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | រមាសឈរ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ព្រៃធំ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ចំរេះ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| ៤ | កណ្តាល | ស្អាង | ព្រែកអំបិល | អន្លង់តាសេក | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ព្រែកក្រាញ់ | ទីជនបទ | ២ | ២ | ០ | ១ | ៥ |
| | | | | សំប៉ានលើ | ទីជនបទ | ២ | ២ | ១ | ១ | ៦ |
| | | | | កូនជ្រៃ | ទីជនបទ | ២ | ២ | ២ | ០ | ៦ |
| | | | | ត្រើយត្រឹង | ទីជនបទ | ២ | ២ | ២ | ០ | ៦ |
| | កណ្តាល | ស្អាង | ស្វាយប្រទាល | ប៉ារែនក្រោម | ទីជនបទ | ២ | ៣ | ២ | ១ | ៨ |
| | | | | ព្រែកតាជ័រ | ទីជនបទ | ២ | ២ | ២ | ០ | ៦ |
| | | | | ពោធិ៍តាប៉ាង | ទីជនបទ | ១ | ២ | ១ | ២ | ៦ |
| | | | | ឫស្សីជ្រោយ | ទីជនបទ | ២ | ២ | ១ | ០ | ៥ |
| | | | | ព្រែកតាសៅ | ទីជនបទ | ២ | ២ | ០ | ១ | ៥ |
| | កណ្តាល | កោះធំ | សំពៅពូន | កោះទៀវក | ទីជនបទ | ២ | ៣ | ០ | ៣ | ៨ |
| | | | | ខ្ពប | ទីជនបទ | ២ | ២ | ១ | ១ | ៦ |
| | | | | កំពង់ថ្កុល | ទីជនបទ | ១ | ២ | ១ | ២ | ៦ |
| | | | | កប៉ាល់គឿង | ទីជនបទ | ២ | ២ | ១ | ០ | ៥ |
| | | | | ក្បាលកោះទៀវ | ទីជនបទ | ២ | ២ | ២ | ០ | ៦ |
| | កណ្តាល | តាខ្មៅ | តាខ្មៅ | តាខ្មៅ | ទីប្រជុំជន | ៣ | ៣ | ២ | ២ | ១០ |
| | | | | ព្រែកសំរោង | ទីប្រជុំជន | ៤ | ៤ | ៣ | ៤ | ១៥ |
| | | | | ថ្មី | ទីប្រជុំជន | ៣ | ៣ | ១ | ២ | ៩ |
| | កណ្តាល | កោះធំ | ព្រែកស្តី | ពោធិ៍រាម្នា | ទីជនបទ | ២ | ៣ | ១ | ២ | ៨ |
| | | | | ព្រែកតាមេម | ទីជនបទ | ២ | ២ | ១ | ០ | ៥ |
| | | | | ព្រែកប៉ុក | ទីជនបទ | ២ | ២ | ០ | ២ | ៦ |
| | | | | ប្រជាតុ | ទីជនបទ | ១ | ២ | ១ | ០ | ៤ |
| | | | | ចុងព្រែក | ទីជនបទ | ២ | ២ | ២ | ០ | ៦ |
| ៥ | កំពង់ចាម | ស្ទឹងត្រង់ | ព្រែកបាក់ | ព្រែកបាក់ | ទីជនបទ | ៣ | ៣ | ២ | ២ | ១០ |

# ឧបសម្ព័ន្ធ

| កូដ | ខេត្ត | ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ការចាត់ថ្នាក់តំបន់ | ប្រជាជនទូទៅ | | អ្នករស់រានមានជីវិត | | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| | | | | ព្រៃកកក់ | ទីជនបទ | ៣ | ៣ | ២ | ៣ | ១១ |
| | | | | ព្រៃករលួស | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ព្រៃកព្រះអង្គ | ទីជនបទ | ៣ | ២ | ២ | ២ | ៩ |
| | កំពង់ចាម | ចំការលើ | ស្វាយទាប | ថ្នល់បែកកើត | ទីជនបទ | ២ | ៣ | ០ | ១ | ៦ |
| | | | | ស្វាយទាប | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | តាំងក្រង់ | ទីជនបទ | ២ | ២ | ១ | ២ | ៧ |
| | | | | បុសថ្លាន់ | ទីជនបទ | ២ | ២ | ១ | ២ | ៧ |
| | | | | ថ្នល់បែកកើត | ទីជនបទ | ២ | ២ | ១ | ១ | ៦ |
| | កំពង់ចាម | ចំការលើ | បុសខ្នុរ | បុសខ្នុរ | ទីជនបទ | ២ | ៣ | ១ | ៣ | ៩ |
| | | | | ១០មករា | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ថ្នល់ក្រវ៉ាន់ | ទីជនបទ | ១ | ២ | ១ | ២ | ៦ |
| | | | | សាមគ្គី | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ប្រសើរ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | កំពង់ចាម | ព្រៃឈរ | បារាយ | ព្រៃខ្វាយ | ទីជនបទ | ២ | ៣ | ១ | ២ | ៨ |
| | | | | ទួលចំបក់ | ទីជនបទ | ១ | ២ | ០ | ២ | ៥ |
| | | | | ពោលជ្រូក | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | ត្រពាំងបេង | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | អូរកំបោរ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | កំពង់ចាម | ចំការលើ | ចំការអណ្ដូង | លេខពីរ | ទីជនបទ | ២ | ៣ | ១ | ២ | ៨ |
| | | | | ចំការអណ្ដូង | ទីជនបទ | ២ | ២ | ១ | ២ | ៧ |
| | | | | សាមសិបបី | ទីជនបទ | ១ | ២ | ១ | ២ | ៦ |
| | | | | លេខដប់មួយ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| | | | | សូរដៃ | ទីជនបទ | ២ | ២ | ២ | ២ | ៨ |
| សរុប | | | | | | ២៤២ | ២៧៧ | ២១០ | ២៤១ | ៩៧០ |






Photo by Sous Sakal / Documentation Center of Cambodia Archives

# តារាងគំនូសតាង


គំនូសតាងទី១: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យហ៊ុន សែន (ចាត់ថ្នាក់តាមភេទ សំណាកនិងកម្រិតសិក្សាអប់រំ) ..... 76

គំនូសតាងទី២: កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 77

គំនូសតាងទី៣: កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 79

គំនូសតាងទី៤: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យក្រសួងយុត្តិធម៌ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 80

គំនូសតាងទី៥: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យសាកលវិទ្យាលយ័ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 82

គំនូសតាងទី៦: កម្រិតនៃការយល់ស្របចំពោះបណ្ណសារដ្ឋានជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 83

គំនូសតាងទី៧: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 85

គំនូសតាងទី៨: កម្រិតនៃការយល់ស្របចំពោះរាជបណ្ឌិត្យសភាកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 86

គំនូសតាងទី៩: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យព្រឹទ្ធសភា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 88

គំនូសតាងទី ១០: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 89

គំនូសតាងទី ១១: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 90

គំនូសតាងទី ១២: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារច្បាប់ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 90

គំនូសតាងទី ១៣: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យក្រសួងយុត្តិធម៌ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 91

គំនូសតាងទី ១៤: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 91

គំនូសតាងទី ១៥: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណសារដ្ឋានជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 92




/// ឧបសម្ពន្ធ ///


គំនូសតាងទី ១៦: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 92

គំនូសតាងទី ១៧: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅរាជបណ្ឌិត្យសភាកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 93

គំនូសតាងទី ១៨: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យព្រឹទ្ធសភា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 93

គំនូសតាងទី ១៩: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យផ្សេងៗក្នុងស្រុក (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 94

គំនូសតាងទី ២០: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅសាកលវិទ្យាល័យផ្សេងៗក្រៅស្រុក (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 94

គំនូសតាងទី ២១: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅស្ថាប័នអន្តរជាតិផ្សេងទៀត/អង្គការក្រៅរដ្ឋាភិបាលក្រៅស្រុក (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 95

គំនូសតាងទី ២២: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅស្ថាប័នផ្សេងៗទៀត (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ) ..... 95

## កំនូសតាងទី១: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យហ៊ុន សែន (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៧.១ តើអ្នកយល់ស្រប និងមិនយល់ស្របកម្រិតណាចំពោះប្រយោគខាងក្រោម? (តាមភេទ)
បណ្ណាល័យសម្ដេចហ៊ុន សែន ...




Q៣៧.១ តើអ្នកយល់ស្រប និងមិនយល់ស្របកម្រិតណាចំពោះប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក)
បណ្ណាល័យសម្ដេចហ៊ុន សែន ...








Q៣៧.១ តើអ្នកយល់ស្រប និងមិនយល់ស្របកម្រិតណាចំពោះប្រយោគខាងក្រោម? (តាមកំរិតសិក្សាអប់រំ)
បណ្ណាល័យសម្ដេចហ៊ុន សែន ...




## កំនូសតាងទី២: កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៧.២ តើអ្នកយល់ស្រប និងមិនយល់ស្របកម្រិតណាចំពោះប្រយោគខាងក្រោម? (តាមភេទ)
មជ្ឈមណ្ឌលឯកសារកម្ពុជា ...



Q៣៧.២ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក)
មជ្ឈមណ្ឌលឯកសារកម្ពុជា ...




Q37.2 តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក)
មជ្ឈមណ្ឌលឯកសារកម្ពុជា ...








## គំនូសតាងទី៣: កម្រិតនៃការយល់ស្របចំពោះមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៧.៣ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមភេទ)
មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ...




Q37.3 តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក)
មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ...



**Q៣៧.៣ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមកំរិតសិក្សាអប់រំ)**
**មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ...**




## គំនូសតាងទី៤: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យក្រសួងយុត្តិធម៌ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

**Q៣៧.៤ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមភេទ)**
**បណ្ណាល័យក្រសួងយុត្តិធម៌ ...**






/// ឧបសម្ព័ន្ធ ///

**Q៣៧.៤ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក)**
**បណ្ណាល័យក្រសួងយុត្តិធម៌ ...**




**Q៣៧.៤ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមកម្រិតសិក្សាអប់រំ)**
**បណ្ណាល័យក្រសួងយុត្តិធម៌ ...**



## គំនូសតាងទី៥: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)










## គំនូសតាងទី៦: កម្រិតនៃការយល់ស្របចំពោះបណ្ណសារដ្ឋានជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)



Q៣៧.៦ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក)
បណ្ណសារដ្ឋានជាតិកម្ពុជា ...




Q៣៧.៦ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមកម្រិតសិក្សាអប់រំ)
បណ្ណសារដ្ឋានជាតិកម្ពុជា ...








## គំនូសតាងទី៧: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៧.៧ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមបណ្ណាល័យជាតិ)




Q៣៧.៧ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមថ្នាក់តាមសំណាក)



Q៣៧.៧ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមកម្រិតសិក្សាអប់រំ)




គំនូសតាងទី៨: កម្រិតនៃការយល់ស្របចំពោះរាជបណ្ឌិត្យសភាកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ))

Q៣៧.៨ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមភេទ) រាជបណ្ឌិត្យសភាកម្ពុជា




Q៣៧.៨ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក) រាជបណ្ឌិត្យសភាកម្ពុជា




Q៣៧.៨ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមកម្រិតសិក្សាអប់រំ)



## គំនូសតាងទី៩: កម្រិតនៃការយល់ស្របចំពោះបណ្ណាល័យព្រឹទ្ធសភា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៧.៩ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមភេទ) បណ្ណាល័យព្រឹទ្ធសភា



Q៣៧.៩ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (ចាត់ថ្នាក់តាមសំណាក) រាជបណ្ឌិត្យសភាកម្ពុជា







Q៣៧.៩ តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាជាមួយប្រយោគខាងក្រោម? (តាមកម្រិតសិក្សាអប់រំ) បណ្ណាល័យព្រឹទ្ធសភា



## គំនូសតាងទី ១០: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៨.២.១ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សា)



## គំនូសតាងទី ១១: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៨.២.២ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅ បណ្ណាល័យសម្តេចហ៊ុន សែន (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)




## គំនូសតាងទី ១២: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារច្បាប់ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៨.២.៣ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)








## គំនូសតាងទី ១៣: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យក្រសួងយុត្តិធម៌ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៨.២.៤ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅ បណ្ណាល័យក្រសួងយុត្តិធម៌ (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)




## គំនូសតាងទី ១៤: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

Q៣៨.២.៥ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅ បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)



### គំនូសតាងទី ១៥: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណសារដ្ឋានជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

**Q៣៨.២.៦ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណសារដ្ឋានជាតិកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)**




### គំនូសតាងទី ១៦: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

**Q៣៨.២.៧ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យជាតិ (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)**








### គំនូសតាងទី ១៧: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅរាជបណ្ឌិត្យសភាកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

**Q៣៨.២.៨ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅរាជបណ្ឌិត្យសភាកម្ពុជា (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)**




### គំនូសតាងទី ១៨: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យព្រឹទ្ធសភា (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)

**Q៣៨.២.៩ វាពិតជាល្អណាស់ដែលឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យព្រឹទ្ធសភា (ចាត់ថ្នាក់តាមភេទ សំណាក និងតាមកម្រិតសិក្សាអប់រំ)**



## គំនូសតាងទី ១៩: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅបណ្ណាល័យផ្សេងៗក្នុងស្រុក (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)




## គំនូសតាងទី ២០: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅសាកលវិទ្យាល័យផ្សេងៗក្រៅស្រុក (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)




## គំនូសតាងទី ២១: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅស្ថាប័នអន្តរជាតិផ្សេងទៀត/អង្គការក្រៅរដ្ឋាភិបាលក្រៅស្រុក (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)




## គំនូសតាងទី ២២: ឯកសារ និងកំណត់ត្រានៃដំណើរការកាត់ក្តីរបស់ អ.វ.ត.ក ត្រូវបានរក្សាទុកនៅស្ថាប័នផ្សេងៗទៀត (ចាត់ថ្នាក់តាមភេទ សំណាក និងកម្រិតសិក្សាអប់រំ)



## មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកបានអនុម័តឲ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាចូលជាធរមាន ដោយលោកប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការកោតសរសើរនិងមេដាយជាច្រើនសម្រាប់កិច្ចការគាំទ្រឲ្យមានការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងឆ្នាំ ២០០៧តែមួយប៉ុណ្ណោះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលពានរង្វាន់សិទ្ធិមនុស្ស ជូឳិត លី ស្រ្តូណាច់ ពីមជ្ឈមណ្ឌលសម្រាប់ការទទួលខុសត្រូវនិងយុត្តិធម៌។ ព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី ទ្រង់បានព្រះរាជទានគ្រឿងឥស្សរយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់ធិបឌិន្ទដល់លោក ឆាំង យុ ក្នុងការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងឆ្នាំ ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានឈ្នះពានរង្វាន់ រ៉ាម៉ុន ម៉ាក់សៃសៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ីសម្រាប់ការថែរក្សានិងការចងចាំប្រវត្តិសាស្រ្តសម្រាប់ការព្យាបាលរបួសផ្លូវចិត្តនិងយុត្តិធម៌។

ខណ្ឌចំការមន, រាជធានីភ្នំពេញ (១២៣០១), កម្ពុជា
ទូរស័ព្ទ៖ +៨៥៥ (០)២៣ ២១១ ៨៧៥
អ៊ីមែល៖ dccam@online.com.kh
គេហទំព័រ៖ www.dccam.org

**អៀង សារី ហៅ វ៉ាន់** - កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩២៥ នៅភូមិលឿងវ៉ា ឃុំលឿងវ៉ាខេត្តត្រាវិញ ប្រទេសវៀតណាម។ អៀង សារី បានសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកបានទៅសិក្សានៅប្រទេសបារាំង។ អៀង សារី បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានធ្វើជាគ្រូបង្រៀនផ្នែកប្រវត្តិសាស្រ្ត នៅក្នុងឆ្នាំ ១៩៥៧។ អៀង សារី ត្រូវបានចោទប្រកាន់ពីបទបានចូលរួមជាមួយចលនាខ្មែរក្រហមក្នុងឆ្នាំ ១៩៦៣។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៃរបបប៉ុលពត អៀង សារី គឺជាសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាល និងមានតួនាទីជាឧបនាយករដ្ឋមន្រ្តីនិងជារដ្ឋមន្រ្តីក្រសួងការបរទេស។ អៀង សារី ត្រូវបានជឿជាក់ថាមានតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនសមាជិករបស់ខ្លួនជាច្រើននាក់ពីក្រសួងបរទេសទៅកាន់មន្ទីរស-២១ ដែលជាទីកន្លែងពួកគេត្រូវបានវាយសួរចម្លើយនិងប្រហារជីវិត។ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានផ្តួលរំលំនៅក្នុងឆ្នាំ១៩៧៩ អៀង សារី ត្រូវបានផ្តន្ទាទោសពីបទប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ និងត្រូវបានកាត់ទោសប្រហារជីវិតកំបាំងមុខ ដោយតុលាការប្រជាជនបដិវត្តកម្ពុជា។ នៅក្នុងឆ្នាំ ១៩៩៦ អៀង សារី រួមជាមួយនឹងអ្នកគាំទ្ររបស់ខ្លួនរាប់ពាន់នាក់ទៀត បានផ្តាច់ខ្លួនចេញពីចលនាខ្មែរក្រហម តាមរយការប្តូរទៅនឹងការលើកលែងទោសពីអតីតព្រះមហាក្សត្រសម្តេចព្រះនរោត្តមសីហនុ។ សម្រាប់ការកាត់ទោសប្រហារជីវិតនិងការសន្យា អៀង សារី នឹងមិនត្រូវបានផ្តន្ទាទោសដោយយោងតាមច្បាប់ក្នុងឆ្នាំ១៩៩៤ ដែលបានចែងថា អង្គការខ្មែរក្រហមគឺជាអង្គការខុសច្បាប់។ នៅពេលនោះ អៀង សារី បានផ្លាស់ទីលំនៅមករស់នៅក្នុងទីក្រុងភ្នំពេញជាមួយប្រពន្ធរបស់ខ្លួនគឺ អៀង ធីរិទ្ធ។ ក្រោយមក អៀង សារី ត្រូវបានចាប់ខ្លួនដោយរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ និងបានបញ្ជូនទៅជំនុំជម្រះក្តីដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក្នុងសំណុំរឿង០០២។ អៀង សារី បានទទួលមរណភាព នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣។



*ថតរូបដោយ៖ ឆាំង យុ, ប៉ៃលិន ឆ្នាំ១៩៩៩ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា*









**អៀង ធីរិទ្ធ (ខៀវ ធីរិទ្ធ) ហៅ ភា** - កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្នុងទីក្រុងភ្នំពេញ។ អៀង ធីរិទ្ធ បានសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកបានទទួលសញ្ញាបត្រផ្នែកអក្សរសាស្រ្តអង់គ្លេសនៅប្រទេសបារាំង។ អៀង ធីរិទ្ធ បានរៀបការជាមួយ អៀង សារី នៅក្នុងឆ្នាំ១៩៥១។ ខៀវ ប៉ុណ្ណារី គឺជាបងស្រីរបស់ អៀង ធីរិទ្ធ ហើយបានរៀបការជាមួយប៉ុល ពត។ អៀង ធីរិទ្ធ បានត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ១៩៥៧ ហើយបានធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៃសម័យប៉ុលពត អៀង ធីរិទ្ធ គឺជាសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាល និងមានតួនាទីជារដ្ឋមន្រ្តីក្រសួងសង្គមកិច្ចនិងការងារ។ អៀង ធីរិទ្ធ ត្រូវបានបញ្ជូនឲ្យចុះទៅពិនិត្យមើលនិងរាយការណ៍អំពីបញ្ហាសុខភាពនៅក្នុងភូមិភាគពាយ័ព្យ។ ដូច្នេះ អៀង ធីរិទ្ធ គឺប្រហែលជាបានដឹងថា ប្រជាជនកម្ពុជាយ៉ាងច្រើននាក់កំពុងរងភាពអត់ឃ្លាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អៀង ធីរិទ្ធ ក៏ត្រូវបានចោទប្រកាន់អំពីបទជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួននិងការសម្លាប់បុគ្គលិករបស់ខ្លួនមួយចំនួនក្នុងក្រសួងកិច្ចការសង្គមនិងការងារ។ នៅក្នុងឆ្នាំ១៩៩៦ អៀង ធីរិទ្ធ រួមជានឹងមួយស្វាមី បានផ្តាច់ខ្លួនចេញពីក្រុមខ្មែរក្រហម។ ក្រោយមកអៀង ធីរិទ្ធ ត្រូវបានរាជរដ្ឋាភិបាលចាប់ខ្លួនជាមួយនឹងប្តី ហើយត្រូវបានបញ្ជូនទៅជំនុំជម្រះក្តីដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ក្នុងសំណុំរឿង០០២។ អៀង ធីរិទ្ធ បានទទួលមរណភាព នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ។



ប៉ុលពត និង ចិនៈ ភ្នំពេញថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ (រូបកណ្ដាលខាងស្ដាំ)៖ ប៉ុលពត គឺជានាយករដ្ឋមន្ត្រី និងជាលេខាបក្សកុម្មុយនីស្ដកម្ពុជា (ប.ក.ក) ជាមួយ វ៉ាំង ដុង ស៊ុន គឺជាអនុប្រធានគណៈកម្មាធិការកណ្ដាលនៃបក្សកុម្មុយនីស្ដចិន។ (រូបពីក្រោយ វ៉ាំងដុងស៊ីន)៖ ខៀវ សំផន គឺជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ (រូបដំបូងខាងឆ្វេង)៖ ហ៊្វ យ៉ាវ បាង គឺជាអគ្គលេខាធិការគណៈកម្មាធិការកណ្ដាលបក្សកុម្មុយ នីស្ដចិន។ (រូបទីពីរខាងឆ្វេង)៖ នួន ជា ប្រធានសភាតំណាងប្រជាជន និងជាអនុលេខាបក្សកុម្មុយនីស្ដកម្ពុជា។ នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ សាលាក្ដីខ្មែរក្រហមបានផ្ដន្ទាទោស នួន ជា និង ខៀវ សំផនពីបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៤៩។ អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទបទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តនៅទីតាំងផ្សេងៗពីគ្នាទូទាំងប្រទេសកម្ពុជាក្នុងកំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ប៉ុល ពត គឺជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៦ ហើយបានចុះចេញពីតំណែងរបស់ខ្លួនក្នុងឆ្នាំ១៩៧៩ ប៉ុន្តែ ប៉ុល ពត នៅតែជាមេដឹកនាំយ៉ាងសកម្មរបស់ខ្មែរក្រហម។ ប៉ុល ពត បានរស់នៅក្នុងសភាពនិរទេសខ្លួនហើយភាគច្រើនគឺនៅក្នុងប្រទេសថៃ។ រហូតដល់ថ្ងៃទី១៥ ខែមេសាឆ្នាំ១៩៩៨ ប៉ុល ពត បានស្លាប់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។ សពរបស់ ប៉ុល ពត ត្រូវបានបូជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨។ នៅថ្ងៃទី៤ ខែសីហាឆ្នាំ២០១៩ នួន ជា បានស្លាប់នៅចំពាក់កណ្ដាលនិតិវិធីនៃការប្ដឹងឧទ្ធរណ៍របស់ចៅក្រមនិងអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ វគ្គ២។



រដ្ឋមន្ត្រីក្រសួងការពារជាតិ និង សន្តិសុខរបស់ខ្មែរក្រហម សុន សេន និងប្រធានគណៈប្រតិភូវៀតណាម ង្វៀនស៊្វឹន ហ្វង់ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញក្នុងខែសីហា ឆ្នាំ១៩៧៥ ។

(រូបថតឯកសារ) បណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលសារកម្ពុជា។

ឧបត្ថម្ភគាំទ្រដោយៈ
ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក